**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**


## សារណាបញ្ចប់ការសិក្សា

# ការដោះស្រាយទំនាស់ដីធ្លីនៅកម្ពុជា៖ ករណីនៅអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

ស្រាវជ្រាវពីថ្ងៃទី ០២ ខែ មិថុនា ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៥


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ជួន ពិសី**

ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ:

ជំនាន់ទី៨

សាស្ត្រាចារ្យណែនាំ

លោកបណ្ឌិត **ហាប់ ផល្លី**



ឆ្នាំចូលសិក្សា ២០១១

ឆ្នាំសរសេរសារណា ២០១៥

# សេចក្តីថ្លែងអំណរគុណ

ជាដំបូងខ្ញុំបាទ សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោកអ្នកដ៏មានគុណជាទីស្រលាញ់ និងជាទីគោរព គឺអ្នកម្តាយ **អោក អុន** ដែលបានលះបង់ជីវិតដើម្បីផ្តល់កំណើតដល់រូបកូន ព្រមទាំងបានតស៊ូលំបាក់វេទនាខិតខំចិញ្ចឹមបីបាច់ថែរក្សា ដោយផ្តល់នូវដង្ហើមដ៏មានអត្ថន័យដែលកូនអាចរស់រានមានជីវិត។ លោកអ្នកមានគុណបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការជួយទំនុបបម្រុងទាំងផ្នែកស្មារតី និងសភារៈឲ្យរូបកូនមានភាពកក់ក្តៅនៅក្នុងចិត្ត ដែលជំរុញទឹកចិត្តកូនឲ្យចេះតស៊ូ និងខិតខំប្រឹងប្រែងសិក្សារៀនសូត្រ។ បងប្រុស **ជួនអន្តជា** បងស្រី **ជួនសុម៉ាលី** ដែលបានលះបង់នូវកម្លាំងកាយកម្លាំងចិត្តយ៉ាងច្រើន ក្នុងការងារដើម្បីឲ្យប្អូនបានបន្តការសិក្សារហូតដល់កម្រិតនេះ។ **ព្រះតេជគុណ ញឹម សម្បត្តិ** ដែលបានផ្តល់ជាកន្លែងស្នាក់នៅដល់រូបខ្ញុំ។

ម្យ៉ាងវិញទៀត ខ្ញុំសូមថ្លែងអំណរគុណដល់ **មជ្ឈមណ្ឌលអប់រំ ស្រាវជ្រាវអំពីច្បាប់ជប៉ុននៃសាកលវិទ្យាល័យណាហ្គោយ៉ាប្រចាំកម្ពុជា** សាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់ដែលបានផ្តល់ឱកាសដល់រូបខ្ញុំបានសិក្សាភាសា និងច្បាប់ជប៉ុនដោយឥតគិតថ្លៃរយៈពេល ៤ឆ្នាំ។ ក្នុងរយៈពេល ៤ឆ្នាំមកនេះ ធ្វើឲ្យរូបខ្ញុំបានទទួលចំណេះដឹងផ្នែកភាសា និងច្បាប់ជប៉ុន។ ពិសេសជាងនេះរូបខ្ញុំទទួលបានចំណេះដឹងថ្មីៗបន្ថែមទៀតទាក់ទងនឹងការសិក្សាស្រាជ្រាវផ្នែកច្បាប់ ដែលនេះជាឱកាសដែលកម្ររកបាន។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណចំពោះ **លោកសាស្ត្រាចារ្យបណ្ឌិត ហាប់ ផល្លី** ដែលជាសាស្ត្រាចារ្យណែនាំ ដោយលោកបានលះបង់កម្លាំងកាយ កម្លាំងចិត្ត យកចិត្តទុកដាក់ រួមទាំងពេលវេលាដ៏មានតម្លៃក្នុងការជួយពន្យល់ណែនាំ និងតម្រង់ផ្លូវ រហូតដល់សម្រេចបាននូវកិច្ចការស្រាវជ្រាវនេះឡើង។

# អារម្ភកថា

សារណានេះ បានធ្វើឡើងក្នុងឱកាសនៃការបញ្ចប់ការសិស្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ជំនាន់ទី៨។ ហើយពេលនេះ គឺជាឱកាសមួយដ៏ល្អកម្ររកបាន ដែលបានផ្តល់ភាពក្នុងការបង្ហាញសមត្ថភាព ចំណេះដឹងដែលបានសន្សំទុកអស់រយៈ៤ឆ្នាំមកនេះ មកធ្វើការចូលរួមលើកឡើងអំពីបញ្ហាសង្គមបច្ចុប្បន្ន និងផ្តល់ដំណោះសមស្របមួយលើបញ្ហានោះតាមរយៈការស្រាវជ្រាវ។

កម្ពុជា បានជួបប្រទះសង្គ្រាមស៊ីវិលរ៉ាំរ៉ៃអស់រយៈពេលជាច្រើនឆ្នាំ ហើយទើបតែមានសន្តិភាពពេញលេញនៅឆ្នាំ ១៩៩៩។ ស្ថិតនៅក្នុងស្ថានភាពទើបងើបពីសង្គ្រាម កម្ពុជាបានស្ថិតក្នុងដំណាក់កាលនៃការធ្វើកំណែទម្រង់លើគ្រប់វិស័យ។ ហើយនៅក្នុងនោះ កំណែទម្រង់លើវិស័យដីធ្លីក៏ជាវិស័យមួយដែលមានអាទិភាពផងដែរ។ ទទឹមនឹងមានការខិតខំប្រឹងប្រែងនេះ ទំនាស់ដីធ្លីបានកើតឡើង និងរីកដុះដាលគ្រប់ទីកន្លែងទូទាំងផ្ទៃប្រទេស។ នេះដោយសារតែ បញ្ហាកង្វះខាតនូវដំណោះស្រាយសមស្រប ទើបបណ្តាលឲ្យទំនាស់ដីធ្លីវិវត្តខ្លួនក្លាយទៅជាបញ្ហាស្មុគស្មាញ ដែលបង្កឲ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់សង្គមជាតិទាំងមូល។ ហើយមូលហេតុដំបូង និងចម្បងនៃទំនាស់ដីធ្លីគឺការកើនឡើងនូវតម្លៃដីក្រោយពីកម្ពុជាបានធ្វើឯកជនភាវូបនីយកម្មនៅឆ្នាំ ១៩៨៩។ ប៉ុន្តែក្រោយមកទៀត មូលហេតុធ្វើឲ្យកើតមានទំនាស់ដីធ្លីក៏មានការប្រែទៅតាមការវិវត្តសង្គម និងសេដ្ឋកិច្ចផងដែរ។

សារណានេះ ក៏ជាផ្លែផ្ការមួយដែលកើតចេញពីបាតុភាពនៃបញ្ហាខាងលើ ធ្វើឲ្យមានការចាប់អារម្មណ៍ផ្ទាល់ខ្លួន ហើយជំរុញឲ្យធ្វើការស្រាវជ្រាវលើបញ្ហានេះ។ សារណានេះ បានធ្វើការវិភាគដោយផ្តោតសំខាន់លើបញ្ហានៃយន្តការដោះស្រាយទំនាស់ ដែលឈរនៅពីក្រោយដំណោះស្រាយដែលអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីបានអនុវត្តកន្លងមក ដោយស្វែងយល់អំពីស្ថានភាពជាក់ស្តែង និងវិភាគរកដំណោះស្រាយមួយឲ្យសមស្រប ដោយក្តីរំពឹងថា អាចនឹងចូលរួមចំណែកក្នុងការដោះស្រាយទំនាស់ដីធ្លីនៅកម្ពុជាឲ្យមានប្រសិទ្ធភាព។

ទោះជាយ៉ាងណាក៏ដោយ ដោយសារតែចំណេះដឹង និងបទពិសោធន៍ក្នុងការសិក្សាស្រាវជ្រាវនៅមានកម្រិតនៅឡើយ សារណានេះច្បាស់ជាមានចំណុចខ្វះខាត និងខ្វះចន្លោះតិចឬច្រើនដោយជៀសមិនផុតនោះទេ។ ហេតុដូច្នេះ មតិយោបល់ និងការរិះគន់ គឺជាអ្វីដែលមិនអាចខ្វះបានដើម្បីកែលម្អ និងអភិវឌ្ឍសមត្ថភាពស្រាវជ្រាវឲ្យមានភាពប្រសើរឡើងនាពេលអនាគត។

# មាតិកា


សេចក្តីផ្តើម...1

ជំពូកទី១ សញ្ញាណទូទៅនៃទំនាស់ដីធ្លី...3

១.១. សញ្ញាណទូទៅនៃដីរដ្ឋ...3

១.១.១. ការវិវត្តដីរដ្ឋ...3

១.១.១.១. ដីរដ្ឋមុនឯកជនភាវូបនីយកម្ម...4

១.១.១.២. ដីរដ្ឋក្រោយឯកជនភាវូបនីយកម្ម...6

១.២. បច្ចុប្បន្នភាពនៃដីរដ្ឋ...10

១.២.១. ប្រភេទនៃដីរដ្ឋ...10

១.២.២ ការចុះបញ្ជីដីធ្លី...13

ជំពូកទី២ បច្ចុប្បន្នភាពនៃទំនាស់ដីធ្លី...16

២.១. ទិដ្ឋភាពទូទៅនៃទំនាស់ដីធ្លី...16

២.១.១. កត្តាដែលបណ្តាលឲ្យមានទំនាស់ដីធ្លី...17

២.១.១.១ កត្តាដែលកើតចេញប្រជាពលរដ្ឋ...17

២.១.១.២. កត្តាដែលកើតចេញពីអាជ្ញាធរ...19

២.១.២. លក្ខណៈពិសេសនៃទំនាស់ដីធ្លី...21

២.១.២.១. ប្រភេទដីដែលជាកម្មវត្ថុនៃទំនាស់...21

២.២. ផលប៉ះពាល់ដែលកើតចេញពីទំនាស់ដីធ្លី...22

២.២.១. ផលប៉ះពាល់ចំពោះប្រជាពលរដ្ឋ...22

២.២.១.១. ការបាត់បង់ដីធ្លីដែលកំពុងកាន់កាប់...22

២.២.២. ផលប៉ះពាល់ចំពោះសង្គមជាតិទាំងមូល...23

២.២.២.១. ផលប៉ះពាល់លើសង្គម និងសេដ្ឋកិច្ច ........ 23

២.២.២.២. ផលប៉ះពាល់ដល់សិទ្ធិមនុស្ស ........ 24

**ជំពូកទី៣ ដំណោះស្រាយទំនាស់ដីធ្លីនៅអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី** ........ 26

**៣.១. ដំណោះស្រាយដែលធ្លាប់អនុវត្តកន្លងមក** ........ 26

៣.១.១. ដំណោះស្រាយតាមរយៈការដោះស្រាយបណ្ដឹង ........ 26

៣.១.២. ដំណោះស្រាយតាមរយៈការចុះអប់រំ និងផ្សព្វផ្សាយ ........ 27

**៣.២. ការវិភាគលើមូលដ្ឋាននៃដំណោះស្រាយរួម** ........ 28

៣.២.១. ប្រសិទ្ធភាពនៃដំណោះស្រាយ ........ 28

**សេចក្ដីសន្និដ្ឋាន** ........ 32

**អនុសាសន៍** ........ 34

**ឯកសារយោង** ........ 35

# សេចក្តីផ្តើម

បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាកំពុងអនុវត្តការងាររបស់ខ្លួនយ៉ាងសសាក់សស្រាំទាក់ទងទៅនឹងកំណែទម្រង់ការគ្រប់គ្រងដីធ្លីនៅកម្ពុជាដែលក្នុងនោះរាជរដ្ឋាភិបាលបានដាក់ចេញជាគោលនយោបាយសាធារណៈ ហើយគោលនយោបាយទាំងនោះថែមទាំងបានបញ្ចូលទៅក្នុង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ផងដែរ។ ក្នុងដំណាក់កាលកំណែទម្រង់ការគ្រប់គ្រងដីធ្លីនេះរាជរដ្ឋាភិបាលបានយកច្បាប់ភូមិបាលឆ្នាំ ២០០១ធ្វើជាមូលដ្ឋានគ្រឹះដើម្បីទទួលស្គាល់កម្មសិទ្ធិឯកជនលើដីធ្លី តាមរយៈការបែងចែកដីធ្លីជូនប្រជាពលរដ្ឋដោយគោរពទៅតាមលទ្ធកម្មពិសេសនៃភោគៈ។ ក៏ប៉ុន្តែស្របពេលគ្នានេះដែរ ទំនាស់ដីធ្លីដែលទាក់ទងទៅនឹងសិទ្ធិនៅលើដីធ្លី ជាបញ្ហាដែលកើតឡើងយ៉ាងផុសផុលនៅទូទាំងប្រទេសគួរឲ្យកត់សម្គាល់ផងដែរ។ នៅក្នុងទិដ្ឋភាពដីដែលមានទំនាស់នេះ ជាទូទៅតែងតែមានគូភាគីដែលជាក្រុមប្រជាពលរដ្ឋរាប់សិបគ្រួសារ ឬជាអ្នកតំណាងរបស់ប្រជាពលរដ្ឋ និងភាគីម្ខាងទៀតដែលមានសមាសភាពដូចជា រាជរដ្ឋាភិបាល អាជ្ញាធរថ្នាក់ជាតិ-ក្រោមជាតិ ឬក្រុមហ៊ុនវិនិយោគជាដើម គឺជាទំនាស់ដីធ្លីដែលមានសភាពធ្ងន់ធ្ងរ។ ផលប៉ះពាល់ដែលកើតចេញពីទំនាស់ដីធ្លីនេះគឺមានឥទ្ធិពលយ៉ាងខ្លាំងចំពោះប្រជាពលរដ្ឋ ដែលជាហេតុនាំឲ្យមានការព្រួយបារម្ភកាន់តែខ្លាំង។ ទំនាស់ដីធ្លីបែបនេះ គឺបានកើតឡើងនៅពេលដែលរាជរដ្ឋាភិបាល ក៏ដូចជាអាជ្ញាធរបានធ្វើការចាត់ចែងបែងចែកដីធ្លីដែលជាកម្មវត្ថុនៃទំនាស់ទាំងអស់នោះ ទៅឲ្យក្រុមហ៊ុនវិនិយោគដីធ្លីធ្វើការអភិវឌ្ឍក្រោមរូបភាពដីសម្បទានសេដ្ឋកិច្ច ឬអាជ្ញាធរមានសមត្ថកិច្ចខ្លួនឯងផ្ទាល់បានធ្វើការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាការ្យសាធារណៈផ្សេងទៀតដើម្បីបំរើផលប្រយោជន៍សាធារណៈ។ ទាក់ទងទៅនឹងបញ្ហាទំនាស់ដីធ្លីនេះរាជរដ្ឋាភិបាល បានដាក់ចេញនូវក្របខ័ណ្ឌច្បាប់ និងបទដ្ឋានគតិយុត្តទាក់ទងនឹងដីធ្លីជាច្រើនគួរឲ្យកត់សម្គាល់ផងដែរ ដើម្បីធ្វើការដោះស្រាយទំនាស់ដីធ្លីដែលចេះតែកើនឡើងស្ទើរតែរាល់ថ្ងៃនេះ។ ទន្ទឹមនឹងការបង្កើតក្របខ័ណ្ឌច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងដីធ្លី រាជរដ្ឋាភិបាលក៏បានបង្កើតស្ថាប័នថ្មីមួយទៀតដែលមានឈ្មោះថា **អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី** ក្នុងគោលបំណងដោះស្រាយទំនាស់ដីធ្លីនៅកម្ពុជាឲ្យកាន់តែមានប្រសិទ្ធភាព។ ប៉ុន្តែ ទោះបីជាអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីត្រូវបានបង្កើតឡើងក៏ដោយ ក៏ទំនាស់ដីធ្លីនៅតែមិនថមថយបន្តិចសោះឡើយ ។ ម្យ៉ាងវិញទៀតនៅឆ្នាំបន្តបន្ទាប់ទំនាស់ដីធ្លីនៅតែបន្តកើតឡើង និងរីករាលដាលពេញផ្ទៃប្រទេសដដែល។ បញ្ហាដែលអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមិនអាចដោះស្រាយបាន ដោយសារតែអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមិនមានយន្តការទប់ស្កាត់ទំនាស់។

បញ្ហាកង្វះខាតយន្តការទប់ស្កាត់ទំនាស់ដីធ្លី នៅអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីនេះ កើតមានតាំងពីដើមដំបូងនៃការបង្កើតអាជ្ញាធរមកម្លេះ។ ប៉ុន្តែគិតមកដល់ពេលនេះ មិនសូវមានការសិក្សាស្រាវជ្រាវ ទាក់ទងនឹងប្រសិទ្ធភាព និងយន្តការទប់ស្កាត់ទំនាស់ឲ្យបានសមស្របនៅក្នុងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីនោះទេ បើទោះបីជាមានការសិក្សាស្រាវជ្រាវកន្លងមកទាក់ទងនឹងដីធ្លី ព្រមទាំងគណៈកម្មការសុរិយោដីទាំងបីថ្នាក់ក៏ដោយ។ ក្នុងនេះអាចនឹងមានការចោទសួរថា តើអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីបង្កើតឡើងដើម្បីអ្វី បើទំនាស់ដីធ្លីនៅតែបន្តកើនឡើងយ៉ាងដូចច្នេះ? តើមានកត្តាអ្វីខ្លះទៅ ដែលបណ្តាលឲ្យអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមិនអាចដោះស្រាយ និងទប់ស្កាត់ទំនាស់ដីធ្លីដោយមានប្រសិទ្ធភាព? ហើយទាក់ទងនឹងបញ្ហានេះ តើរាជរដ្ឋាភិបាលមានយន្តការ និងដំណោះស្រាយបែបណាខ្លះ ដើម្បីជួយសម្រួលដល់ដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។ មកទល់នឹងពេលនេះ ចម្លើយទាក់ទងទៅសំនួរខាងលើ នៅតែមិនទាន់មានចម្លើយណាមួយបកស្រាយឲ្យជាក់លាក់ និងច្បាស់លាស់នៅឡើយទេ។ ភាពមិនច្បាស់លាស់ក្នុងការស្វែងរកឬសគល់ ឬសញ្ញាណនៃទំនាស់ដីធ្លី វានាំឲ្យបញ្ហាទំនាស់ដីធ្លីមិនអាចដោះស្រាយបានដោយប្រសិទ្ធភាព និងធ្វើឲ្យស្ថានភាពគតិយុត្តរបស់អ្នកកាន់កាប់ដីធ្លីមិនមានស្ថេរភាព។ លើសពីនេះទៅទៀត គឺធ្វើឲ្យបញ្ហាទំនាស់ដីធ្លីចេះតែរីកដុះដាលឥតឈប់ឈរ ដែលជាហេតុបង្កឲ្យមានផលប៉ះយ៉ាងខ្លាំងដល់សង្គមជាតិទាំងមូល។ ដើម្បីឆ្លើយតបនឹងសំនួរខាងលើនេះ គឺវាទាមទារឲ្យមានការសិក្សាស្រាវជ្រាវមួយយ៉ាងល្អិតល្អន់ និងជាក់លាក់តាមបែបវិទ្យាសាស្ត្រ។

សារណានេះ មានគោលបំណងធ្វើការសិក្សាស្វែងយល់អំពីប្រភព និងឬសគល់នានារួមទាំងបញ្ហាច្បាប់ផងដែរ ដែលទាក់ទងទៅនឹងការដោះស្រាយទំនាស់ដីធ្លីនៅអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងធ្វើការវែកញែកដោយលើកបង្ហាញអំពីទិដ្ឋភាពបច្ចុប្បន្នរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី រួចវិភាគលើការដោះស្រាយកន្លងមក និងផ្តល់ជូននូវដំណោះស្រាយមួយសមស្រប។

សារណានេះ ធ្វើការស្រាវជ្រាវដោយផ្អែកទៅលើឯកសារសំខាន់ៗដូចជា៖ របាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាល របាយការណ៍របស់រដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងស្ថាប័នពាក់ព័ន្ធនឹងទំនាស់ដីធ្លី ក៏ដូចជាការដោះស្រាយទំនាស់ដីធ្លីនៅអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមកធ្វើជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវ។

សារណានេះ ចែកចេញជា៣ជំពូក។ ជំពូកទី១ បង្ហាញអំពីសញ្ញាណទូទៅនៃទំនាស់ដីធ្លី។ ជំពូកទី២ បកស្រាយអំពីបច្ចុប្បន្នភាពនៃទំនាស់ដីធ្លី។ ចំណែកជំពូកទី៣វិញ នឹងលើកបង្ហាញអំពីការដោះស្រាយទំនាស់ដីធ្លីនៅអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។

# ជំពូកទី១ សញ្ញាណទូទៅនៃទំនាស់ដីធ្លី

ប្រភេទនៃដីធ្លីនៅកម្ពុជា ត្រូវបានបែងចែកចេញជាពីរប្រភេទធំៗ គឺដីរដ្ឋ និងដីឯកជន។ ប៉ុន្តែដីធ្លីមួយភាគធំ ដែលក្នុងនោះរួមបញ្ចូលទាំងដីរដ្ឋផងដែរនោះ គឺមិនទាន់ទទួលបានការកំណត់អត្តសញ្ញាណកម្ម និងកំណត់អំពីព្រំប្រទល់ឲ្យបានច្បាស់លាស់នៅឡើយទេ។ ការណ៍នេះ បានបង្កឲ្យមានការកាន់កាប់ដីធ្លីយ៉ាងអានាធិបតេយ្យ និងនាំឲ្យកើតមានបញ្ហាទំនាស់ដីធ្លីស្ទើរតែគ្រប់ទីកន្លែង នៅពេលដែលរាជរដ្ឋាភិបាលធ្វើការបែងចែកដីជូនប្រជាពលរដ្ឋ និងធ្វើការអភិវឌ្ឍនៅលើដីធ្លីនោះ។

ជំពូកនេះ លើកឡើងអំពីសញ្ញាណទូទៅនៃដីរដ្ឋ ដែលធ្វើការរៀបរាប់លម្អិតអំពីការវិវត្តដីរដ្ឋ (១.១) ម្យ៉ាងវិញទៀត នឹងលើកអំពីបច្ចុប្បន្នភាពនៃដីរដ្ឋមកធ្វើការបកស្រាយ(២.១)។

## ១.១. សញ្ញាណទូទៅនៃដីរដ្ឋ

រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ មាត្រា៥៨[1] គឺមានចែងអំពីដីរដ្ឋ ហើយនិងមានរាយនូវឈ្មោះ រាល់ទ្រព្យសម្បត្តិទាំងឡាយណាដែលចាត់ចូលជាទ្រព្យសម្បត្តិរដ្ឋ។ ម្យ៉ាងវិញទៀត ច្បាប់ភូមិបាលឆ្នាំ ២០០១ ក៏បានបញ្ញត្តលម្អិតបន្ថែមទៀតទាក់ទងនឹងដីរដ្ឋផងដែរ ដោយធ្វើការបញ្ជាក់ និងបែងចែកដីរដ្ឋជាប្រភេទ។ ក្រៅពីបទដ្ឋានគតិយុត្តសំខាន់ទាំងពីរខាងលើនេះ នៅឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យមួយផ្សេងទៀត ដើម្បីគ្រប់គ្រងដីរដ្ឋ នោះគឺអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ រាល់ការគ្រប់គ្រង និងប្រើប្រាស់ដីរដ្ឋ គឺត្រូវអនុវត្តដោយអនុលោមតាមអនុក្រឹតនេះ។ ក្នុងចំណុចនេះ នឹងសិក្សាអំពីការវិវត្តនៃដីរដ្ឋចាប់តាំងពីឆ្នាំ១៩៧៩ មកដល់ពេលបច្ចុប្បន្ន(១.១.១) ហើយនឹងលើកយកបច្ចុប្បន្នភាពនៃដីរដ្ឋមកធ្វើការបកស្រាយរួមមានដូចជាការចុះបញ្ជីដីធ្លីជាដើម។

### ១.១.១. ការវិវត្តដីរដ្ឋ

របបដីធ្លីកម្ពុជាមានការផ្លាស់ប្តូរយ៉ាងគំហុកពីឆ្នាំ ១៩៧៥ ដល់១៩៧៩ ដែលស្ថិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ របបនេះ បានធ្វើឲ្យកម្ពុជាគ្របដណ្តប់ដោយវាំងននងងឹត ហើយជាសម័យកាលមួយដែលមានសង្គ្រាមរ៉ាំរ៉ៃ[2] ដែលជាហេតុនាំឲ្យអត្ថបទច្បាប់ ឯកសារ សៀវភៅបញ្ជី និង

---

[1] ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃ ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែលបានកំណត់ថាជារបស់រដ្ឋ។

[2] អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, *របាយការណ៍ និងសកម្មភាពការងារឆ្នាំ២០០៩,* (ភ្នំពេញ៖ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី នាយកដ្ឋានទប់ស្កាត់ បង្ការ និងអប់រំ, ឧសភា ២០១០), ១។

ឧបករណ៍បច្ចេកទេសសំខាន់នានាដែលទាក់ទងនឹងដីធ្លី ត្រូវបានបាត់បង់ស្ទើរតែទាំងស្រុង។[3] គួរបញ្ជាក់ផងដែរថា នៅក្នុងរបបនេះ ប្រជាពលរដ្ឋគឺមិនមានកម្មសិទ្ធិឯកជនលើដីធ្លីទេ ដីធ្លីទាំងអស់ត្រូវបានរឹបអូសដើម្បីជារបស់រដ្ឋ ហើយត្រូវបានគ្រប់គ្រងផ្តាច់មុខ ដែលមានអង្គការជាកម្មសិទ្ធិករ។[4] ដោយមានភាពលំបាក និងបញ្ហាជាច្រើនដែលកើតឡើងទាក់ទងនឹងការទទួលស្គាល់កម្មសិទ្ធិឯកជនលើដីធ្លី សិទ្ធិកម្មសិទ្ធិដីធ្លីត្រូវបានចាប់ផ្តើមទទួលស្គាល់សារជាថ្មីម្តងទៀត[5] ដោយរដ្ឋបែងចែកកម្មសិទ្ធិដាច់ឲ្យគ្រួសារប្រជាពលរដ្ឋកម្ពុជា លើលំនៅដ្ឋាន។[6] ក៏ប៉ុន្តែ ការទទួលស្គាល់កម្មសិទ្ធិឯកជនលើដីធ្លីនេះ មិនទទួលស្គាល់កម្មសិទ្ធិមុនរបបកម្ពុជាប្រជាធិបតេយ្យឡើយ។[7] ចាប់តាំងពីមានការទទួលស្គាល់នូវរបបកម្មសិទ្ធិឯកជនលើដីធ្លី បន្ទាប់ពីការវិនាសហិនហោចនូវរបបកម្ពុជាប្រជាប្រជាធិបតេយ្យ ដីធ្លីមានការវិវត្តគួរឲ្យកត់សម្គាល់ ដោយសារតែឯកជនភាវូបនីយកម្មឆ្នាំ ១៩៨៩បានឈានមកដល់ ការចាប់បដិសន្ធិឡើងនៃឯកជនភាវូបនីយកម្មនេះ បានធ្វើឲ្យដំណើរការវិវត្តនៃដីរដ្ឋ លេចចេញឡើងជាពីរដំណាក់កាល ដំណាក់កាលទី១ គឺដីរដ្ឋមុនឯកជនមុនភាវូបនីយកម្ម (១.១.១.១.) ហើយដំណាក់កាលទី២ ដីរដ្ឋក្រោយឯកជនភាវូបនីយកម្ម (១.១.១.២)។

### ១.១.១.១. ដីរដ្ឋមុនឯកជនភាវូបនីយកម្ម

ក្រោយពីកម្ពុជាបានឆ្លងកាត់របបដ៏សាហាវយង់ឃ្នងនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី ០៧ មករា ១៩៧៩មក របបថ្មីសម្រាប់កម្ពុជាមួយទៀតក៏បានចាប់កំណើតឡើងផងដែរ នោះគឺរបបសង្គមនិយម នៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា។ របបថ្មីមួយនេះ បានប្រកាសឲ្យប្រើ រដ្ឋធម្មនុញ្ញរបស់ខ្លួនលើកដំបូងនៅថ្ងៃទី ២៧ មិថុនា ១៩៨១ ដោយក្រឹត្យ លេខ០១ក្រ ចុះថ្ងៃទី ២៧ មិថុនា ១៩៨១ របស់ក្រុមប្រឹក្សារដ្ឋក្រោយពី រដ្ឋសភាបានអនុម័តជាឯកច្ឆ័ន្ទ។[8] នៅក្នុងរដ្ឋធម្មនុញ្ញខាងលើនេះ ដីធ្លី ព្រៃឈើ សមុទ្រ ទន្លេ បឹង ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ មូលដ្ឋាន

---

[3] East-West Management Institute, *ច្បាប់ភូមិបាលកម្ពុជា៖ សៀវភៅសិក្សា និងស្រាវជ្រាវ* (ភ្នំពេញ, ២០០៥), ២៦។; ហៃល ចំរើន, "ទស្សនាទាននៃសិទ្ធិលើកម្មសិទ្ធិដីធ្លីនៅកម្ពុជា", *វិស្សបវត្តិ* ២០០២~២០០៣(២០០៥)៖ ២៨,២៩។

[4] ហៃល ចំរើន, "ទស្សនាទាននៃសិទ្ធិលើកម្មសិទ្ធិដីធ្លីនៅកម្ពុជា", *វិស្សបវត្តិ* ២០០២~២០០៣(២០០៥)៖ ២៩។

[5] ហៃល ចំរើន, "ទស្សនាទាននៃសិទ្ធិលើកម្មសិទ្ធិដីធ្លីនៅកម្ពុជា", *វិស្សបវត្តិ* ២០០២~២០០៣(២០០៥)៖ ៣០។; ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ កម្មសិទ្ធិឯកជនលើដីធ្លី ត្រូវបានគេទទួលលើកដំបូង នាសន្និបាតកម្មការិបាលទូទាំងប្រទេសលើកទី២ ខែមេសា ឆ្នាំ១៩៨៩ ក្នុងសេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី។

[6] អនុក្រឹត្យស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា, លេខ២៥អនក្រ ២២ មេសា ១៩៨៩, មាត្រា២ កថាខណ្ឌទី១។

[7] សេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣ សណន ០៣ មិថុនា ១៩៨៩។; ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា១។; ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៧។

[8] ហៃល ចំរើន, "ពិចារណាមួយលើវិវាទដីធ្លីនៅកម្ពុជា", *វិស្សបវត្តិ* (២០០៧), ៤៨។

ការពារប្រទេស និងសំណង់ផ្សេងៗទៀត[9] ត្រូវបានចាត់ទុកជាកម្មសិទ្ធិរបស់រដ្ឋ។ លើសពីនេះទៅទៀត ក្នុងរដ្ឋធម្មនុញ្ញដដែលនេះ មិនឃើញមានមាត្រាណាមួយ ដែលចែងឲ្យច្បាស់លាស់អំពីកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋនៅលើដីរដ្ឋនោះទេ ឃើញមានតែមាត្រាដែលចែងពីកម្រៃការងារ និងកម្រៃដែលប្រជាពលរដ្ឋមានលើព្រទ្យសម្បត្តិតែប៉ុណ្ណោះ។[10]

ដើម្បីសម្រួលដល់កិច្ចដំណើរការគ្រប់គ្រងលើដីធ្លី និងដើម្បីកំណត់ក្របខ័ណ្ឌគតិយុត្តសម្រាប់សិទ្ធិប្រើប្រាស់ដីធ្លី រដ្ឋអំណាចបាន ដាក់ចេញនូវអនុក្រឹត្យមួយស្តីពី ការគ្រប់គ្រងដីធ្លីកសិកម្ម។ តាមរយៈអនុក្រឹត្យនេះ រដ្ឋអំណាចគ្រប់លំដាប់ថ្នាក់ តាំងពីថ្នាក់កណ្តាលរហូតដល់ថ្នាក់មូលដ្ឋាន ទទួលបានសិទ្ធិពេញទី ក្នុងនាមជាអ្នកគ្រប់គ្រង និងប្រើប្រាស់ដីធ្លីទូទៅ តាមព្រំប្រទល់ដែលស្ថិតនៅក្នុងភូមិសាស្ត្ររដ្ឋបាលរបស់ខ្លួន។[11] រដ្ឋអំណាច ជាអ្នកធ្វើការបែងចែកដី និងប្រគល់ដីកសិកម្ម[12]ឲ្យទៅគ្រួសារកសិករ កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ដែលរស់នៅក្នុងមូលដ្ឋានផ្ទាល់ សម្រាប់សាងសង់លំនៅដ្ឋាន និងធ្វើសេដ្ឋកិច្ចដើម្បីបម្រើប្រយោជន៍គ្រួសារ។[13] ពិសេសជាងនេះទៅទៀត ការប្រគល់ដីធ្លីកសិកម្មនេះ រដ្ឋអំណាចបានផ្តល់ អាទិភាពយ៉ាងពិសេស ដល់ក្រុមសាមគ្គីបង្កបង្កើនផលកសិដ្ឋានរដ្ឋ និងសាលាបណ្តុះបណ្តាលបច្ចេកទេសកសិកម្មជាដើម ក្នុងគោលបំណងជំរុញឲ្យមានការផលិតឲ្យបានច្រើនតាមផែនការកំណត់របស់រដ្ឋ។[14]

អំពីប្រជាពលរដ្ឋវិញ ប្រជាពលរដ្ឋមានសិទ្ធិពេញទីក្នុងការប្រើប្រាស់ និងមានសិទ្ធិតំណមរតកលើដីធ្លី ដែលរដ្ឋបានប្រគល់មកឲ្យខ្លួន ដើម្បីប្រើប្រាស់សង់លំនៅដ្ឋាន និងធ្វើជាសួនច្បារសួនបន្លែ។[15] ក្រៅពីដីសម្រាប់សាងសង់ផ្ទះសម្បែង ដីសម្រាប់ធ្វើជាសួនច្បារបន្លែ និងក្រៅពីដីដែលក្រុមសាមគ្គីបង្កបង្កើនផលប្រគល់ឲ្យសម្រាប់ បំពេញផលិតកម្មរបស់ក្រុមពលករ កសិករគ្រប់រូប អាចត្រូវបានរដ្ឋឲ្យខ្ចីដីបន្ថែម ដើម្បីធ្វើជាដីដាំដំណាំតាមលទ្ធភាពពលកម្ម ហើយនឹងមានសិទ្ធិទទួលបានផលនៃការងារនេះ។[16] ទោះបីជារដ្ឋអំណាច បានធ្វើការបែងចែកដីធ្លី និងផ្តល់សិទ្ធិពេញទីក្នុងការប្រើប្រាស់

[9] រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, លេខ០១ក្រ, ២៧ មិថុនា ១៩៨១, មាត្រា១៩។

[10] រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, លេខ០១ ក្រ, ២៧ មិថុនា ១៩៨១, មាត្រា១៨។

[11] អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រើប្រាស់ដីកសិកម្ម, លេខ០៦ អនក្រ, ០៦ ឧសភា ១៩៨៥, មាត្រា១ កថាខ័ណ្ឌទី២ វ័ក្យខ័ណ្ឌទី១ មាត្រា១។

[12] ដីធ្លីកសិកម្មមាន ដីស្រែ វាលរាប ដីស្រែខ្ពង់រាប ដីទួល ដីព្រៃដែលមានការអនុញ្ញាត ដីចម្ការ ដីតាមមាត់ទន្លេ ដីកោះ វាលស្មៅធម្មជាតិ(អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រើប្រាស់ដីកសិកម្ម, លេខ០៦ អនក្រ, ០៦ ឧសភា ១៩៨៥, មាត្រា១ កថាខ័ណ្ឌទី១)។

[13] អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រើប្រាស់ដីកសិកម្ម, លេខ០៦ អនក្រ, ០៦ ឧសភា ១៩៨៥, មាត្រា២ កថាខ័ណ្ឌទី២។

[14] ដូច ១៣។

[15] រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, លេខ០១ ក្រ, ២៧ មិថុនា ១៩៨១, មាត្រា១៥។

[16] រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, លេខ០១ ក្រ, ២៧ មិថុនា ១៩៨១, មាត្រា១៦។

ដីធ្លីជូនប្រជាពលរដ្ឋយ៉ាងណាក៏ដោយ សិទ្ធិក្នុងការប្រើប្រាស់ដីធ្លីដែលប្រជាពលរដ្ឋម្នាក់ៗកំពុងតែមាននេះ នៅតែមានការកម្រិតសិទ្ធិនៅលើដីធ្លី និងមានការរឹតត្បិតច្រើនថែមទៀតផង។ ជាក់ស្តែងប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែប្រើប្រាស់ផ្ទាល់ខ្លួន និង សិទ្ធិអាស្រ័យផលធម្មជាតិលើដីធ្លី ដែលរដ្ឋចែកឲ្យប្រើប្រាស់តាមគ្រួសារតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលគ្រួសារណាមួយលែងបង្កបង្កើនផល ឬមួយត្រូវផ្លាស់ប្តូរទីលំនៅទៅកាន់កន្លែងផ្សេងទៀត តាមរយៈហេតុផលត្រឹមត្រូវ និងដោយបានទទួលការអនុញ្ញាតពីរដ្ឋអំណាចមូលដ្ឋាន គ្រួសារនោះនឹងត្រូវប្រគល់ដីធ្លីដែលខ្លួនប្រើប្រាស់ឲ្យទៅរដ្ឋអំណាចវិញ។[17] ជាងនេះទៅទៀតនោះ គ្មានជនណាម្នាក់ ដែលមានសិទ្ធិទិញ លក់ បញ្ចាំ ឬ ប្រវាស់ដីធ្លីបានឡើយ ហើយប្រជាពលរដ្ឋក៏មិនអាចប្រើប្រាស់ដីធ្លីកសិកម្ម ដីព្រៃ ដោយចិត្តឯងក្នុងគោលបំណងផ្សេងទៀតបានទេ ប្រសិនបើគ្មានការអនុញ្ញាតជាមុនពីក្រសួងមានសមត្ថកិច្ច។[18] ដូច្នេះ យោងទៅតាម មាត្រា ៥ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងប្រើប្រាស់ដីកសិកម្ម គ្រួសារនីមួយៗអាចប្រើប្រាស់ដីកសិកម្មចំនួនបីប្រភេទគឺៈ ១.ដីធ្លីសម្រាប់សាងសង់លំនៅដ្ឋាន និងដីសម្រាប់ធ្វើសេដ្ឋកិច្ចគ្រួសារ ក្នុងនោះគិតទាំងចម្ការគ្រួសារដែលរដ្ឋអំណាចបានប្រគល់ឲ្យប្រើប្រាស់តាមការកំណត់ និងតាមគោលនយោបាយរបស់រដ្ឋ ២.ដីធ្លីដែលត្រូវបានគេបោះបង់ចោល ហើយរដ្ឋអំណាចបានអនុញ្ញាតឲ្យស្តារឡើងវិញ ឬឲ្យកាប់គាស់រានបន្ថែម ៣.ដីធ្លីដែលក្រុមសាមគ្គីបង្កបង្កើនផលបានប្រគល់ឲ្យប្រើប្រាស់មួយរយៈ។ រួមសេចក្តីមក ប្រជាពលរដ្ឋនៅតែពុំទាន់មានសិទ្ធិកាន់កាប់ដីធ្លីណាមួយដោយចិត្តខ្លួនឯងបានឡើយ រាល់ការកាន់កាប់ដីធ្លីណាក៏ដោយ ចាំបាច់ត្រូវតែមានការបែងចែកពីរដ្ឋអំណាចជាមុនសិន។[19] គួរបញ្ជាក់ឡើយវិញ រដ្ឋអំណាចត្រូវបានហាមឃាត់ដាច់ខាត ក្នុងការទិញ លក់ ប្រវាស់ ជួលដី ជួលដីបឹង ឬ ជួលពលករធ្វើលើដី ទោះបីជាស្ថិតក្រោមរូប។[20]

### ១.១.១.២. ដីរដ្ឋក្រោយឯកជនភាវូបនីយកម្ម

ឯកជនភាវូបនីយកម្មដីធ្លីបានចាប់កំណើតឡើងក្នុងឆ្នាំ ១៩៨៩ ដោយមានការផ្តល់សិទ្ធិលើដីធ្លីឯកជន។ នេះមានន័យថា ដីធ្លីទាំងឡាយណាដែលជាកម្មវត្ថុនៃដីឯកជន វាមិនមែនជាដីរដ្ឋទៀតទេ។ ការផ្តល់សិទ្ធិឯកជនលើដីធ្លីនេះ វាមានសិទ្ធិជាច្រើនយ៉ាងតាមរយៈការវិវត្តរបស់ប្រព័ន្ធ ប៉ុន្តែដោយឡែកនៅត្រង់ចំណុចនេះ លើកយកតែ ភោគៈ និង កម្មសិទ្ធិមកសិក្សាតែប៉ុណ្ណោះ ដោយហេតុថា សិទ្ធិ

[17] អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រើប្រាស់ដីកសិកម្ម, លេខ០៦ អនក្រ, ០៦ ឧសភា ១៩៨៥, មាត្រា៥។
[18] រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, លេខ០១ ក្រ, ២៧ មិថុនា ១៩៨១, មាត្រា១៧។
[19] ហ៊ែល ចំរើន, "ពិចារណាមួយលើវិវាទដីធ្លីនៅកម្ពុជា", *ស្បេបវត្តិ* (២០០៧), ៨៩។
[20] អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រើប្រាស់ដីកសិកម្ម, លេខ០៦ អនក្រ, ០៦ ឧសភា ១៩៨៥។

ទាំងពីរនេះ ជាសិទ្ធិសំខាន់ និងចម្បងបំផុតក្នុងការកំណត់អត្តសញ្ញាណថាតើម្នាក់កាន់កាប់ និងម្ចាស់កម្មសិទ្ធិលើដីធ្លីជានរណា?

ដើមឡើយ ក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា "សិទ្ធិលើទ្រព្យសម្បត្តិផ្ទាល់ខ្លួនមិនត្រូវបានទទួលស្គាល់ស្ទើរតែពេញអំឡុងពេលនៃរបបនេះ។"[21] ប៉ុន្តែ ក្នុងអំឡុងខែមេសា ឆ្នាំដដែលមានការផ្តល់កម្មសិទ្ធិលើផ្ទះសម្បែងជូនដល់ប្រជាពលរដ្ឋ តាមរយៈអនុក្រឹត្យលេខ ២៥។[22]

> ចាប់ពីថ្ងៃនេះតទៅ រដ្ឋបែងចែកកម្មសិទ្ធិដាច់ឲ្យគ្រួសារជាពលរដ្ឋកម្ពុជា លើលំនៅដ្ឋានដែលគ្រួសាររបស់ខ្លួនកំពុងរស់នៅក្នុងឃុំ-សង្កាត់ទូទាំងប្រទេស ហើយដែលរដ្ឋអំណាចឃុំ-សង្កាត់នោះទទួលស្គាល់។[23]

ក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ មិនមានមាត្រាណាមួយដែលទទួលស្គាល់កម្មសិទ្ធិឯកជនលើដីធ្លីទេ គ្រាន់តែទទួលស្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីតែប៉ុណ្ណោះ[24] ហើយសិទ្ធិដែលបញ្ញត្តនេះគ្រាន់តែសំដៅដល់ ភាពផ្តាច់មុខក្នុងការកាន់កាប់ប្រើប្រាស់ដីធ្លី។រូបភាពនៃការកាន់កាប់ និងប្រើប្រាស់ដីធ្លីនេះ ត្រូវបានបែងចែកជាបីធំៗគឺ ១.កម្មសិទ្ធិ ២.ភោគៈ និង៣.សម្បទាន។[25] នៅដើមខែមិថុនា ឆ្នាំដដែល រដ្ឋអំណាចបានចាប់ផ្តើមទទួលស្គាល់ និងប្រគល់កម្មសិទ្ធិលើដីសម្រាប់សង់លំនៅដ្ឋាន។[26] ហើយការផ្តល់ជូនជាកម្មសិទ្ធិនេះ ត្រូវសម្រេចចេញដោយប្រធានគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង។ ប៉ុន្តែលក្ខណៈក្នុងការវិនិច្ឆ័យសម្រាប់ផ្តល់ជាកម្មសិទ្ធិលើដីលំនៅដ្ឋាននេះ មិនមានចែងនោះទេ។[27] បន្ទាប់មក កម្មសិទ្ធិក្នុងច្បាប់ភូមិបាលឆ្នាំ១៩៩២ មាត្រា១៩បានចែងថាៈ "កម្មសិទ្ធិគឺជាសិទ្ធិដែលច្បាប់បើកឲ្យអាស្រ័យ ឲ្យចាត់ចែងនូវទ្រព្យណាមួយយ៉ាងផ្តាច់ការ និងផ្តាច់មុខតែម្នាក់ឯង កុំឲ្យតែយកវត្ថុនោះទៅប្រើប្រាស់ដោយបទឯណាដែលខុសនឹងច្បាប់បានហើយ។"[28] គិតមកដល់ពេលនេះ កម្មសិទ្ធិឯកជនគឺមិនបានផ្តល់ឲ្យមានលក្ខណៈទូលំទូលាយនៅឡើយទេ ពោលគឺ កម្មសិទ្ធិផ្តល់តែ

---

[21] East-West Management Institute, *ច្បាប់ភូមិបាលកម្ពុជា៖ សៀវភៅសិក្សា និងស្រាវជ្រាវ* (ភ្នំពេញ, ២០០៥), ២៦។

[22] អនុក្រឹត្យស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា, លេខ២៥អនក្រ, ២២ មេសា ១៩៨៩។

[23] អនុក្រឹត្យស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា, លេខ២៥អនក្រ ២២ មេសា ១៩៨៩, មាត្រា២ កថាខណ្ឌទី១។

[24] រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា, ៣០ មេសា ១៩៨៩, មាត្រា១៧។

[25] សេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, មេសា ១៩៨៩។

[26] សេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ០៣ មិថុនា ១៩៨៩។

[27] East-West Management Institute, *ច្បាប់ភូមិបាលកម្ពុជា៖ សៀវភៅសិក្សា និងស្រាវជ្រាវ* (ភ្នំពេញ ២០០៥), ២៦។

[28] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២,មាត្រ១៩ កថាខ័ណ្ឌទី១។

លើដីធ្លីសម្រាប់សាងសង់លំនៅដ្ឋានតែមួយមុខគត់តែប៉ុណ្ណោះ [29] ហើយការទទួលបាននូវកម្មសិទ្ធិនេះ ម្ចាស់កម្មសិទ្ធិត្រូវទិញផ្តាច់ពីរដ្ឋ លើកលែងតែលំនៅដ្ឋាននោះសង់ឡើងដោយថវិការបស់ខ្លួនឯងផ្ទាល់ ឬម្ចាស់លំនៅដ្ឋាននោះជាកម្មាភិបាល បុគ្គលិក កម្មករ កងកម្លាំងប្រដាប់អាវុធ។[30]ម្យ៉ាងវិញទៀត ការទិញផ្តាច់ពីរដ្ឋនេះ ម្ចាស់កម្មសិទ្ធិត្រូវបង់ពន្ធប្រថាប់ត្រា ១០ ភាគរយនៃតម្លៃផ្ទះ។[31] សូមបញ្ជាក់ផងដែរថា គោលការណ៍នេះគឺត្រូវបាន អនុវត្តនៅក្រុងភ្នំពេញ។ [32] តាមរយៈគោលការណ៍នេះ វាអាចនាំឲ្យមានវិវាទកើតឡើងទាក់ទងនឹងកម្មសិទ្ធិលើផ្ទះសំបែង រវាងអ្នកមានលទ្ធភាពទិញផ្ទះដែលមិនបានកាន់កាប់ផ្ទះ ជាមួយអ្នកកាន់កាប់ផ្ទះតែមិនមានលទ្ធភាពទិញផ្តាច់ពីរដ្ឋ ដូច្នេះ គោលការណ៍បែងចែកកម្មសិទ្ធិផ្ទះ ដោយការទិញផ្តាច់ពីរដ្ឋនេះ វាមិនមែនជាគោលនយោបាយមានប្រសិទ្ធភាពទេ បញ្ច្រាសមកវិញវាថែមទាំងបង្កឲ្យមានវិវាទកម្មសិទ្ធិលើផ្ទះទៀតផង។[33] ក្រោយមកទៀត គោលការណ៍នៃការទទួលស្គាល់កម្មសិទ្ធិលើដីធ្លីត្រូវបានបន្តអនុវត្តរហូតដល់ប្រកាសឲ្យប្រើច្បាប់ភូមិបាលថ្មីឆ្នាំ២០០១ ទើបសិទ្ធិលើកម្មសិទ្ធិត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយរួមបញ្ចូលទាំងអចលនវត្ថុទាំងអស់។[34]ពិសេសជាងនេះទៅទៀត កម្មសិទ្ធិឯកជន រួមទាំងកម្មសិទ្ធិលើដីធ្លីផងដែរនោះត្រូវបានធានា និងគាំពារយ៉ាងពេញលេញដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។[35]

ភោគៈកើតឡើងស្របពេលជាមួយគ្នានឹងការទទួលស្គាល់សិទ្ធិលើកម្មសិទ្ធិផងដែរ។ ភោគៈឆ្នាំ១៩៨៩ ផ្តល់ជូន "លើផ្ទៃដីស្រែ ឬចម្ការ។ ដីភោគៈគឺជាដីដែលរដ្ឋប្រគល់សិទ្ធិផ្តាច់មុខជូនដល់គ្រួសារកសិករកាន់កាប់ប្រើប្រាស់ក្នុងពេលធ្វើផលិតកម្ម-អាជីវកម្ម និងបន្តមតិក។"[36]

> ដីភោគៈអាចថេរភាពក្នុងដំណាក់កាលដែលកំពុងប្រើប្រាស់ ពេលឈប់ប្រើប្រាស់គឺលែងជាភោគៈ។[37]

---

[29] អនុក្រឹត្យស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា, លេខ២៥អនក្រ ២២ មេសា ១៩៨៩, មាត្រា២ កថាខណ្ឌទី១។; ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២,មាត្រ១៩ កថាខ័ណ្ឌទី២។; ហៃល ចំរើន, "ពិចារណាមួយលើវិវាទដីធ្លីនៅកម្ពុជា", *ស្សេបវត្តិ* (២០០៧), ៥២។

[30] អនុក្រឹត្យស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា, លេខ២៥អនក្រ ២២ មេសា ១៩៨៩, មាត្រា៥ កថាខណ្ឌទី១។

[31] អនុក្រឹត្យស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា, លេខ២៥អនក្រ ២២ មេសា ១៩៨៩, មាត្រា៧។

[32] សារាចរស្តីពីការផ្តល់កម្មសិទ្ធិ និងលក់ផ្ទះសំបែងជូនប្រជាពលរដ្ឋក្នុងរដ្ឋធានីភ្នំពេញ, លេខ០២សរ, ០៧ កុម្ភៈ ១៩៩១។

[33] ហៃល ចំរើន, "ពិចារណាមួយលើវិវាទដីធ្លីនៅកម្ពុជា", *ស្សេបវត្តិ* (២០០៧), ៥២។

[34] ច្បាប់ភូមិបាល, នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៤។

[35] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា៤៤។

[36] សេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ០៣ មិថុនា ១៩៨៩។

[37] សេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ០៣ មិថុនា ១៩៨៩។

មើលតាមប្រយោគខាងលើ បញ្ជាក់ថា ដីស្រែ ឬចម្ការដែលប្រជាពលរដ្ឋកំពុងតែប្រើប្រាស់គឺជាភោគៈ ប៉ុន្តែភោគៈនេះនឹងរលាយបាត់ទៅវិញនៅពេលណាដែលប្រជាពលរដ្ឋឈប់ប្រើប្រាស់។ "ដីភោគៈនេះ ត្រូវបានផ្តល់ជូនតែចំពោះគ្រួសារណាដែលបានតស៊ូធ្វើស្រែចម្ការ យ៉ាងតិចមួយឆ្នាំមុនថ្ងៃកំណត់នេះ" [38] ហើយដីដែលត្រូវផ្តល់ជូនគឺមានទំហំតិចជាង៥ហិកតា។ [39] នេះមានន័យថាគ្រួសារណាដែលបានចាប់ផ្តើមធ្វើស្រែចម្ការចាប់តាំងពី ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៨ ឬ មុនឆ្នាំនេះនឹងមានសិទ្ធិទទួលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ពីប្រធានគណៈកម្មាធិការប្រជាជនស្រុក ហើយបើពិនិត្យមើលទៅ នេះប្រហែលជាល័ក្ខខ័ណ្ឌតែមួយគត់ដែលសេចក្តីណែនាំបានតម្រូវ ព្រោះមិនឃើញមាន វិធាន ក៏ដូចជាគោលការណ៍ផ្សេងទៀតក្រៅពីនេះទេ។ លើសពីនេះទៀត មិនមែនគ្រាន់តែមិនល័ក្ខខ័ណ្ឌផ្សេងប៉ុណ្ណឹងនោះទេ វិធាន និងគោលការណ៍ចំពោះអ្នកដែលធ្វើស្រែ ឬចម្ការតិចជាងមួយឆ្នាំមុនការកំណត់នេះក៏មិនមានដែរ។ មូលហេតុនេះវាបានក្លាយទៅជាចំណោទបញ្ហាជាខ្លាំងចំពោះគ្រួសារដែលកាន់កាប់ដីស្រែ ឬចម្ការតិចជាងមួយឆ្នាំ ថាតើពួកគាត់អាចទទួលបានភោគៈ ឬយ៉ាងណា? ដូចច្នេះ ភោគៈគឺនៅតែមានបញ្ហារាប់តាំងពីការកើតឡើងមកម្ល៉េះ។

ចំពោះភោគៈក្នុងឆ្នាំ១៩៩២វិញត្រូវបានឲ្យនិយមន័យថា "ជាសភាពការណ៍មួយដែលមានន័យថា កិរិយាកាន់កាប់នូវវត្ថុអ្វីមួយយ៉ាងផ្តាច់មុខតែឯង និងបំពេញចំពោះវត្ថុនោះនូវកិច្ចការទាំងឡាយដូចដែលកម្មសិទ្ធិករបានបំពេញហើយដែរ"។ [40] ក្នុងន័យនេះត្រូវបានគេបកស្រាយថា "ភោគៈសំដៅទៅរកស្ថានភាពដែលនរណាម្នាក់កាន់កាប់ដោយជាក់ស្តែងលើដីមួយកន្លែង ក្នុងគោលបំណងប្រើប្រាស់ផ្ទាល់។" [41] ហើយការកាន់កាប់ជាក់ស្តែងនេះអាចនាំឲ្យភោគីឈានទៅដល់មានអានុភាពចំពោះមុខច្បាប់បាន នៅពេលដែលភោគីបានកាន់កាប់នូវភោគៈនោះ ដោយឥតប្រើហិង្សា ព្យាយាមកាន់កាប់ដោយសុចរិត ឲ្យដឹងឮជាសាធារណៈឥតអាក់ខាន និងឥតព្រលាំ។ [42] និយមន័យភោគៈក្នុងឆ្នាំ១៩៩២នេះ បើប្រៀបធៀបទៅនឹងនិយមន័យភោគៈឆ្នាំ១៩៨៩ឃើញថាវាមានលក្ខណៈខុសគ្នាគួរឲ្យកត់សម្គាល់ ដោយហេតុថាវា មិនជាភោគៈដែល បញ្ជាក់ថារដ្ឋត្រូវតែផ្តល់ឲ្យទេ។ ដូចនេះ តាមខ្លឹមសារខាងលើអាចពន្យល់បានថា ភោគៈសំដៅដល់ការកាន់កាប់ដោយសេរីនៅលើដីធ្លីត្រង់ណាក៏បាន ដោយគ្រាន់តែបំពេញល័ក្ខខ័ណ្ឌឲ្យបានត្រឹមត្រូវ និងពេញលេញដូចដែលមានចែងក្នុងច្បាប់ភូមិបាលឆ្នាំ១៩៩២ មាត្រា៦២ជាការស្រេច។ ប៉ុន្តែចំណុចសំខាន់ ភោគី

---

[38] សេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣ សណន, ០៣ មិថុនា ១៩៨៩។

[39] East-West Management Institute, *ច្បាប់ភូមិបាលកម្ពុជា៖ សៀវភៅសិក្សា និងស្រាវជ្រាវ* (ភ្នំពេញ, ២០០៥), ២៦។

[40] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា៦១។

[41] East-West Management Institute, *ច្បាប់ភូមិបាលកម្ពុជា៖ សៀវភៅសិក្សា និងស្រាវជ្រាវ* (ភ្នំពេញ, ២០០៥), ១១៣។

[42] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា៦២។

ត្រូវប្តឹងសុំការកាន់កាប់លើដីធ្លីដល់ប្រធានឃុំ-សង្កាត់ និងត្រូវបង់ពន្ធលើដីធ្លីឲ្យបានទៀងទាត់ ដើម្បីជាតឹកតាងក្នុងការប្រកាស អំពីការកាន់កាប់ដីធ្លីជាសាធារណៈ។[43] សរុបសេចក្តីមក ភោគៈក្នុងឆ្នាំ ១៩៩២ រដ្ឋអំណាចបានបើកឲ្យមានការកាន់ដីធ្លីយ៉ាងទូទំលាយបំផុត។

## ១.២. បច្ចុប្បន្នភាពនៃដីរដ្ឋ

គ្រង់ចំណុចនេះ និងលើកយកប្រភេទនៃដីរដ្ឋមកបង្ហាញ ដែលក្នុងនោះសិក្សាអំពីដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ (១.២.១) ម្យ៉ាងវិញទៀតនឹងបង្ហាញអំពីការចុះបញ្ជីដីធ្លីផងដែរ។

### ១.២.១. ប្រភេទនៃដីរដ្ឋ

យោងតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ លេខ១១៨ អនក្រ/បក ចុះថ្ងៃទី០៧ តុលា ២០០៥ ដីរដ្ឋ "សំដៅដល់ដីទាំងអស់ដែលជារបស់រដ្ឋ ហើយដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ឬស្ថាប័នថ្នាក់ជាតិ និងដីដែលត្រូវបានប្រគល់ឲ្យនីតិបុគ្គលសាធារណៈ ឬគ្រឹះស្ថានសាធារណៈដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គលដើម្បីកាន់កាប់។"[44] ដីរដ្ឋត្រូវបានបែងចែកជាពីរប្រភេទគឺ ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។[45] ការបែងចែកដីរដ្ឋជាពីរប្រភេទនេះគឺជាគន្លឹះដ៏សំខាន់ក្នុងការស្វែងយល់អំពីនីតិវិធីប្រើប្រាស់ដីទាំងនេះ។[46] គួរបញ្ជាក់ដែរថា ការបែងចែកដីរដ្ឋនេះ ទើបតែត្រូវបានបែងចែកក្នុងច្បាប់ភូមិបាលឆ្នាំ២០០១តែប៉ុណ្ណោះ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ រួមទាំងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣មិនបានការបែងចែករវាងដីសាធារណៈរបស់រដ្ឋ និងដីសាធារណៈឯកជនរបស់រដ្ឋនោះទេ គ្រាន់តែរដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ មាត្រា១៤បានចែងថា៖ "ទ្រព្យសម្បត្តិជាកម្មសិទ្ធិរបស់រដ្ឋមាន ដីធ្លី ព្រៃឈើ សមុទ្រ ទន្លេ បឹង ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ មូលដ្ឋានការពារប្រទេស និងសំណង់ផ្សេងៗទៀតរបស់រដ្ឋ" ហើយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មាត្រា ៥៨បានចែងថា៖ "ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ មូលដ្ឋានការពារប្រទេស និងសំណង់ផ្សេងៗទៀត ដែលបានកំណត់ថាជារបស់រដ្ឋ "តែប៉ុណ្ណោះ។

[43] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា៦៦។

[44] អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨អនក្រ/បក, ០៧ តុលា ២០០៥, មាត្រា២។

[45] ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មត្រា១៩។; អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ, លេខ ១១៨អនក្រ/បក, ០៧ តុលា ២០០៥, មាត្រា ៣។; មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR), *កម្ពុជា៖ ដីមានជម្លោះ ទិដ្ឋភាពនៃស្ថានភាពដីធ្លី* (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ខែធ្នូ ឆ្នាំ២០១៣), ១៧។

[46] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR), *កម្ពុជា៖ ដីមានជម្លោះ ទិដ្ឋភាពនៃស្ថានភាពដីធ្លី* (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ខែធ្នូ ឆ្នាំ២០១៣), ១៧។

តាមរយៈនេះ អាចសន្និដ្ឋានបានថា រដ្ឋធម្មនុញ្ញទាំងពីរខាងលើ គ្រាន់រាយបញ្ជីឈ្មោះអំពីទ្រព្យសម្បត្តិរបស់រដ្ឋ តែ"មិន[បាន]ចែងឲ្យដាច់ពីគ្នារវាងអំពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។"[47]

ដីសាធារណៈរបស់រដ្ឋ "ជាដីដែលមានជាប់ផលប្រយោជន៍សាធារណៈ និងឋិតនៅក្នុងប្រភេទជាក់លាក់នៃទ្រព្យដែលមានផលប្រយោជន៍ជាសាធារណៈ"[48] ពោលមានន័យថា ជាដីសម្រាប់បម្រើដល់ផលប្រយោជន៍សាធារណៈ [49] ហើយប្រភេទជាក់លាក់នៃទ្រព្យដែលមានផលប្រយោជន៍សាធារណៈនេះ គឺមានចែងយ៉ាងក្បោះក្បាយប្រាំពីរប្រភេទនៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១មាត្រា ១៥ ហើយមានការបំពេញបន្ថែមមួយប្រភេទទៀតដោយអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ។[50] ប្រភេទចុងក្រោយនេះ សំដៅទៅលើដីទាំងឡាយណាដែលមានចរិតលក្ខណៈបម្រើផលប្រយោជន៍សាធារណៈ និងដីធ្លីដែលមានមូលដ្ឋានគតិយុត្តិកំណត់រួច។ ក្នុងន័យនេះគឺទាមទារឲ្យមានការបកស្រាយឲ្យបានទូលំទូលាយ។ បើពិនិត្យឲ្យច្បាស់លាស់ ការពង្រីកនៃវិសាលភាព ក៏ដូចជាបញ្ជីឈ្មោះនៃទ្រព្យសម្បត្តិរដ្ឋនេះ មិនមែនទើបតែបញ្ចូលក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋនោះទេ គឺវាបានបញ្ចូលក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣មាត្រា ៥៨ ដោយពង្រីកបញ្ជីបន្ថែមលើរដ្ឋធម្មនុញ្ញ១៩៨១មាត្រា១៥។ លើសពីនេះទៀត នៅឆ្នាំ១៩៩៥ រដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យ[51]មួយទៀតដើម្បីបញ្ជាក់បន្ថែមអំពីទ្រព្យសម្បត្តិរបស់រដ្ឋ។ ការណ៍នេះ រដ្ឋាភិបាលព្យាយាមបង្ហាញពីនិន្នាការក្នុងការពង្រីកវិសាលភាពទ្រព្យសម្បត្តិរបស់រដ្ឋ រួមទាំងការរក្សាទ្រព្យសម្បត្តិរដ្ឋឲ្យមាននិរន្តរភាព។ ប៉ុន្តែការពង្រីកបញ្ជីនេះ រដ្ឋាភិបាលចាំបាច់ត្រូវតែសិក្សាឲ្យបានលម្អិត និងហ្មត់ចត់ជាទីបំផុត ដោយហេតុថា អាចនឹងមានផលប៉ះពាល់ដល់សុវត្ថិភាពដីធ្លីរបស់បុគ្គល ឬក្រុមដែលងាយរងគ្រោះ ជាពិសេសប្រជាពលរដ្ឋដែលមិនមានប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុ។

ចំណែកដីឯកជនរបស់របស់រដ្ឋវិញសំដៅទៅលើ៖

> ដីទាំងអស់ដែលមិនមែនជាដីសាធារណៈរបស់រដ្ឋ និងមិនមែនជាដីដែលកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាពស្របតាមច្បាប់

[47] https://phalthy.files.wordpress.com/2006/11/w11-management-of-state-property.pdf (ចូលទស្សនានៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥)។

[48] អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨អនក្រ/បក, ០៧ តុលា ២០០៥, មាត្រា៥។

[49] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR), *មេរៀនស្តីពី សិទ្ធិដីធ្លីក្នុងច្បាប់ភូមិបាលឆ្នាំ២០០១* (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ២០១៤), ២។

[50] អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨អនក្រ/បក, ០៧ តុលា ២០០៥, មាត្រា៥(ចំណុច ជ)។

[51] អនុក្រឹត្យស្តីពីការប្រកាសទ្រព្យសម្បត្តិរដ្ឋ, លេខ៥៣អនក្រ/បក, ២៧ មិថុនា ១៩៩៥។

ភូមិបាលឆ្នាំ២០០១។ ដីឯកជនរបស់រដ្ឋមានរួមបញ្ចូលដូចជាទ្រព្យនិទាឃាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់ប្រគល់ឲ្យរដ្ឋដោយស្ម័គ្រចិត្ត ឬទ្រព្យដែលមិនអាចកំណត់បាននូវអត្តសញ្ញាណភោគី ឬកម្មសិទ្ធិករស្របច្បាប់។"[52]

យោងតាមន័យខាងលើនេះ ដីឯកជនរបស់រដ្ឋមិនមានសញ្ញាណច្បាស់លាស់ ក្នុងការកំណត់ថាដីឯកជនរបស់រដ្ឋជាដីបែបណាទេ គឺគ្រាន់តែបញ្ជាក់ថា ដីទាំងទាំងឡាយណាក្រៅពីដីសាធារណៈរបស់រដ្ឋ និងដីធ្លីដែលជាកម្មវត្ថុអាចយកជាកម្មសិទ្ធិឯកជនបាន គឺចាត់ទុកថាជាដីឯកជនរបស់រដ្ឋទាំងអស់។ សរុបសេចក្តីមក ដីឯកជនរបស់រដ្ឋគឺជាប្រភេទដីដែលមានសញ្ញាណទូលំទូលាយ ម្យ៉ាងវិញទៀត ជាដីដែលចំណុះឲ្យដីសាធារណៈរបស់រដ្ឋ និងដីជារបស់ឯកជន។ គួរបញ្ជាក់ដែរថា ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ត្រូវបានគ្រប់គ្រងដោយរបបគតិយុត្តិខុសគ្នា។ ជាក់ស្តែង ដីសាធារណៈរបស់រដ្ឋត្រូវបានដាក់ក្រោមរបបគតិយុត្តិពិសេស [53] ក្នុងនោះប្រហែលសំដៅលើរបបគតិយុត្តិផ្នែកនីតិសាធារណៈ ដូចនឹងនីតិរដ្ឋបាលជាដើម។ ចំណែកដីឯកជនរបស់រដ្ឋត្រូវបានគ្រប់គ្រងដោយរបបគតិយុត្តនៃនីតិឯកជនដូចកម្មសិទ្ធិឯកជនដែរ ហើយអាចជាកម្មវត្ថុនៃការលក់ ការដូរ ការបែងចែក ឬការផ្ទេរសិទ្ធិបាន។[54] ផ្ទុយទៅវិញ ដីសាធារណៈរបស់រដ្ឋមិនអាចជាកម្មវត្ថុនៃការលក់ដូរបានឡើយ។[55]

ទោះបីជាមានការកំណត់បែបនេះក៏ដោយ វាមិនមែនមានន័យថា ដីសាធារណៈរបស់មិនអាចលក់ដូរ ឬផ្ទេរសិទ្ធិមិនបាននោះទេ ដីសាធារណៈរបស់រដ្ឋនៅតែអាចជាកម្មវត្ថុនៃការលក់ដូរ ឬផ្ទេរសិទ្ធិបានដដែល នៅពេលណាដីសាធារណៈរបស់រដ្ឋនោះ បានបាត់បង់ផលប្រយោជន៍សាធារណៈ ហើយបានអនុបយោគទៅជាដីឯកជនរបស់រដ្ឋវិញតាមរយៈច្បាប់អនុប្រយោគ។ [56] នេះជាវិធីសាស្ត្រល្អមួយ ដែលអាចឲ្យរដ្ឋធ្វើការផ្ទេរដីសាធារណៈរបស់រដ្ឋ ទៅជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើការចាត់ចែងតាមតម្រូវការជាក់ស្តែង។ ប៉ុន្តែគួរកត់សម្គាល់ដែរថា ក្នុងច្បាប់ដដែលនេះ មិនឃើញមានបទប្បញ្ញត្តិណាមួយចែងអំពី សញ្ញាណលម្អិត និងលក្ខណៈវិនិច្ឆ័យនៃ "ការបាត់បង់ផលប្រយោជន៍សាធារណៈ" នោះទេ។ ការណ៍នេះ បានផ្តល់អំណាចយ៉ាងធំឲ្យទៅរដ្ឋ ក្នុងការចាត់ចែងដីរដ្ឋតាមទំនើងចិត្តរបស់ខ្លួន ដែលអាចនឹងនាំឲ្យដីសាធារណៈរបស់រដ្ឋរួមតូច។ ក្នុងច្បាប់ភូមិបាល

[52] អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨អនក្រ/បក, ០៧ តុលា ២០០៥, មាត្រា៥។
[53] ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា១៥។
[54] ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា១៧។
[55] ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា១៦ កថាខណ្ឌទី១។
[56] ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា១៦ កថាខណ្ឌទី៤។

ទ្រព្យទាំងឡាយរួមទាំងដីដែលកើតឡើងពីធម្មជាតិដូចជាព្រៃឈើ បឹងធម្មជាតិ ដែនបម្រុងធម្មជាតិ បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌-ប្រវត្តសាស្ត្រ និងអចលនវត្ថុជាព្រះរាជទ្រព្យជាដើម មិនមាននិយមន័យណាមួយដែលផ្សារភ្ជាប់នឹងផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ទូទៅនោះទេ។[57] តាមន័យនេះ អាចសន្មតបានថាដីទាំងនេះនឹងមិនត្រូវបានធ្វើអនុបយោគទេ ដែលអាចរក្សានូវទ្រព្យទាំងនេះឲ្យនៅគង់វង្សបាន។ ប៉ុន្តែ អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ បែរជាឲ្យនិយមន័យយ៉ាងទូលំទូលាយចំពោះដីសាធារណៈរបស់រដ្ឋ រួមទាំងទ្រព្យសម្បត្តិខាងលើ ផ្សារភ្ជាប់ជាមួយផលប្រយោជន៍សាធារណៈទាំងអស់ ដែលជាហេតុនាំឲ្យរដ្ឋមានលទ្ធភាពអនុបយោគបានដោយសេរីលើទ្រព្យទាំងអស់នេះ។ ជាក់ស្តែង ក្នុងឆ្នាំ២០១២ "រដ្ឋាភិបាលបានអនុម័តអនុក្រឹត្យចំនួន១៩ ដោយផ្ទេរដី ១០៨.៥២៤ហិកតាពីទ្រព្យសម្បត្តិ[សាធារណៈរបស់រដ្ឋ] ទៅជាទ្រព្យសម្បត្តិ[ឯកជនរបស់រដ្ឋ]" [58] ដែលត្រូវបានសង្ស័យថាយកដីទាំងអស់នោះផ្តល់ជាសម្បទានសេដ្ឋកិច្ច។ ក្នុងនោះរួមមានដីស្ថិតនៅក្នុងតំបន់ការពារ និងដែនបម្រុងធម្មជាតិ ដែលបានបំផ្លិចបំផ្លាញព្រៃឈើ និងធនធានធម្មជាតិផ្សេងទៀតផង។ [59] ដូចនេះ ភាពមិនច្បាស់លាស់នៃសញ្ញាណ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការអនុបយោគខាងលើ អាចជះឥទ្ធិពលមិនល្អដល់ដីសាធារណៈរបស់រដ្ឋយ៉ាងខ្លាំង។

### ១.២.២ ការចុះបញ្ជីដីធ្លី

ដីធ្លីទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវតែចុះបញ្ជី ក្នុងប្រព័ន្ធបញ្ជីសុរិយោដីតាមនីតិវិធីជាធរមានដែលមានចែងក្នុងច្បាប់ភូមិបាលឆ្នាំ២០០១។ ប្រព័ន្ធនៃការចុះបញ្ជីដីធ្លីត្រូវបានបែងចែកជាពីរប្រភេទគឺ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ[60] និងការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។[61] កាលពីមុន ការចុះបញ្ជីដីធ្លីធ្វើឡើងក្នុងគោលបំណងគ្រប់គ្រងការប្រមូលពន្ធដារតែប៉ុណ្ណោះ[62] ប៉ុន្តែបច្ចុប្បន្ននេះ ការចុះបញ្ជីបានដើរតួនាទីយ៉ាងសំខាន់បំផុតក្នុងការកំណត់សម្គាល់អត្តសញ្ញាណអចលនវត្ថុ ឬសិទ្ធិកាន់កាប់អចលនវត្ថុ ជាពិសេសរក្សានូវស្ថេរភាពគតិយុត្តនៃសិទ្ធិប្រាត្យក្ស

[57] ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា១៥។

[58] សមាគមអាដហុក (ADHOC), *ផ្លូវបត់?៖ សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា* (ភ្នំពេញ៖ សមាគមអាដហុក, ២៣ កុម្ភៈ ២០១៣), ១៤។

[59] ដដែល, ១៨, ១៩ និង២៦។

[60] ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ នាំឲ្យទទួលបានប័ណ្ណកម្មសិទ្ធិ, https://phalthy.files.wordpress.com/2006/11/w10-land-registration.pdf (ចូលទស្សនាថ្ងៃទី ១២ កក្កដា ២០១៥)។

[61] ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ នាំឲ្យទទួលបានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬប័ណ្ណភោគៈ, https://phalthy.files.wordpress.com/2006/11/w10-land-registration.pdf (ចូលទស្សនាថ្ងៃទី ១២ កក្កដា ២០១៥)។

[62] East-West Management Institute, *ច្បាប់ភូមិបាលកម្ពុជា៖ សៀវភៅសិក្សា និងស្រាវជ្រាវ* (ភ្នំពេញ, ២០០៥), ២២៣។

ដែលនាំឲ្យបង្កលក្ខណៈងាយស្រួលក្នុងការប្រតិបត្តិការសេដ្ឋកិច្ចប្រចាំថ្ងៃ។[63] ទាក់ទងនឹងការចុះបញ្ជីដីធ្លីនេះ អាចនឹងមានសំនួរថា តើដីធ្លីទាំងអស់ត្រូវបានចុះបញ្ជីរួចហើយ ឬយ៉ាងណា។

ចំពោះចម្លើយខាងលើ មកដល់ពេលនេះដីធ្លីទាំងអស់គឺពុំទាន់ចុះបញ្ជីបានទាំងអស់នៅឡើយទេ ពោលមានន័យថា ការចុះបញ្ជីដីធ្លីមិនទាន់ទទួលបានជោគជ័យនៅឡើយ។ ជាក់ស្តែងរដ្ឋាភិបាលខ្លួនឯងផ្ទាល់ព្រមទទួលស្គាល់ថា ដីរដ្ឋ ទាំងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋភាគច្រើនមិនទាន់បានធ្វើអត្តសញ្ញាណកម្មធ្វើផែនទីកំណត់ទីតាំង និងព្រំប្រទល់ច្បាស់លាស់ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីនៅឡើយ។[64]

ស្របពេលគ្នានេះ ដីឯកជនទាំងអស់នៅទូទាំងប្រទេសមួយចំនួនធំមិនទាន់បានចុះបញ្ជីនៅឡើយទេ។ គិតត្រឹម ខែកញ្ញា ឆ្នាំ២០១៣ រដ្ឋាភិបាលបានផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋបានចំនួន ជាង៣លានប័ណ្ណ តាមរយៈការចុះក្នុងក្របខ័ណ្ឌផែនការទូទៅ និងការអនុវត្តគោលនយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី។[65] គួរឲ្យកត់សម្គាល់ដែរថា នៅបំណាច់ឆ្នាំ២០០៧ ដីដែលចុះបញ្ជីលក្ខណៈជាប្រព័ន្ធមានជាង ១លានក្បាលដី ហើយបានចែកប័ណ្ណ៧០ម៉ឺនក្បាលដី ចំណែកដីដែលចុះបញ្ជីមានលក្ខណៈដាច់ដោយដុំវិញបានចែកប័ណ្ណប្រមាណ ៥៩ម៉ឺនប័ណ្ណ។[66] ដូច្នេះ ចំនួននៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីគិតត្រឹមបំណាច់ឆ្នាំ២០០៧ មកដល់ខែកញ្ញា ឆ្នាំ២០១៣គឺមានការកើនឡើងប្រមាណ១,៧១០,០០០ក្បាល។ ទោះជាចំនួននៃការផ្តល់ប័ណ្ណមានការកើនឡើងយ៉ាងណាក៏ដោយតែចំនួននេះនៅតែស្ថិតនៅក្នុងកម្រិតមួយទាបដដែរ ជាពិសេស "មិនឆ្លើយតបទៅនឹងប្រព័ន្ធទីផ្សារសេរី ដែលប្រជាពលរដ្ឋត្រូវការប័ណ្ណកម្មសិទ្ធិដីធ្លីដើម្បីធានាការកាន់កាប់ដីធ្លី និងលំនៅដ្ឋានរបស់ពួកគេ។"[67]

ការណ៍នៅខាងលើនេះ បានបង្ហាញយ៉ាងច្បាស់ថាដីធ្លីនៅកម្ពុជាពេលបច្ចុប្បន្នពុំទាន់មានព្រំប្រទល់កំណត់ច្បាស់លាស់នៅឡើយទេ។ ភាពមិនច្បាស់លាស់នេះ នាំឲ្យការបែងចែករវាងដីរដ្ឋ

---

[63] អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ១១អនក្រ/បក, ២២ មីនា ២០០០, មាត្រា១៨។

[64] សារាចរស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់, លេខ០២សរ, ២៦ កុម្ភៈ ២០០៧។

[65] យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣។

[66] អ៊ឹម ឈុនលឹម, *បទអន្តរាគមន៍ស្តីពី លទ្ធផលនៃការអនុវត្តកម្មវិធីកំណែទម្រង់ដីធ្លី ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាពសិន្និសីទជាតិរបស់រដ្ឋាភិបាល* (៣០-៣១ ខែឧសភា និង ០១ ខែមិថុនា ឆ្នាំ២០០៨), ១។; ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ, ក្រុមប្រឹក្សាគោលនយោបាយដីធ្លី, *របាយការណ៍ស្តីពី លទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល[សម្រាប់]នីតិកាលទី៣ នៃរដ្ឋសភា ២០០៤-២០០៧ និងទិសដៅបន្ត ពី២០០៨-២០១៣*, (ភ្នំពេញ៖ ០៧ មេសា ២០០៨), ២។

[67] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, *របាយការណ៍សង្ខេបនៃកិច្ចពិភាក្សាតុមូលស្តីពី "កំណែទម្រង់ដីធ្លីនៅកម្ពុជា" ប្រធានបទជាក់លាក់ "ច្បាប់ភូមិបាលឆ្នាំ២០០១"* (ភ្នំពេញ៖ ១៧ កញ្ញា ២០១២), ៤។

និងដីឯកជននៅតែមិនទាន់អាចបែងចែកបាននៅឡើយទេ ម្យ៉ាងវិញទៀតរវាងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរដ្ឋក៏ទំនងជាពុំទាន់មានភាពច្បាស់លាស់ដែរ។ តាមស្ថានភាពមិនច្បាស់លាស់នេះនាំឲ្យដីធ្លីនៅកម្ពុជាបច្ចុប្បន្ន មានការកាន់កាប់លាយឡំគ្នា ដែលនេះជាបញ្ហាប្រឈមយ៉ាងខ្លាំងដែលចាំបាច់ត្រូវតែដោះស្រាយជាបន្ទាន់។

# ជំពូកទី២ បច្ចុប្បន្នភាពនៃទំនាស់ដីធ្លី

បញ្ហានៃទំនាស់ដីធ្លីនៅកម្ពុជា បានកើតឡើងចាប់តាំងពី សិទ្ធិកម្មសិទ្ធិលើដីធ្លី ដែលរាជរដ្ឋាភិបាលបានប្រកាសទទួលស្គាល់នៅឆ្នាំ ១៩៨៩ (តទៅនេះ ការទទួលស្គាល់សិទ្ធិលើកម្មសិទ្ធិ ហៅថាការធ្វើឯកជនភាវូបនីយកម្ម) មកម្ល៉េះ។[68] នៅពេលកម្ពុជាធ្វើឯកជនភាវូបនីយកម្ម ភ្លាមៗដីធ្លីមានតម្លៃទាប ទំនាស់ដីធ្លីមានតិចតួចនៅឡើង ប៉ុន្តែក្រោយមកទៀតនៅពេលដីធ្លីកាន់តែមានតម្លៃថ្លៃនៅលើទីផ្សារ ការរំលោភយកដីធ្លីកើតមានឡើងជាបន្តបន្ទាប់ ដែលជាហេតុនាំឲ្យមានទំនាស់ដីធ្លីស្ទើរគ្រប់ទីកន្លែង។[69] ចំពោះបញ្ហាទំនាស់ដីធ្លីនេះ រដ្ឋាភិបាលខ្លួនឯងផ្ទាល់ក៏ទទួលស្គាល់ដែរ ថាមានការរំលោភយកដីធ្លីតាំងពីមុនរដ្ឋាភិបាលចម្រុះឆ្នាំ១៩៩៣មកម្ល៉េះ។ ក្នុងឆ្នាំ២០០២ រដ្ឋាភិបាលបានបង្កើតគណៈកម្មការសុរិយោដី[70] ក្នុងគោលដៅដោះស្រាយទំនាស់ដីធ្លី។ ក្រោយមកទៀត នៅខែកុម្ភៈ ឆ្នាំ២០០៦ ស្ថាប័នដោះស្រាយទំនាស់ដីធ្លីដ៏ធំមួយទៀតត្រូវបានបង្កើតឡើង នោះគឺអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។ [71] តាមរយៈការបង្កើតស្ថាប័នដោះស្រាយទំនាស់ដីធ្លីមួយហើយមួយទៀតបែបនេះ អាចសន្និដ្ឋានបានថា បញ្ហាទំនាស់ដីធ្លីនៅកម្ពុជាជាបញ្ហាធ្ងន់ធ្ងរ ដែលចាំបាច់ត្រូវតែរកដំណោះស្រាយដោះស្រាយឲ្យមានប្រសិទ្ធភាពជាទីបំផុត។

ដើម្បីជាកូនសោជំរុញឲ្យការដោះស្រាយបញ្ហាទំនាស់ដីធ្លីឲ្យមានប្រសិទ្ធភាព ក្នុងជំពូកនេះ នឹងលើកយកទិដ្ឋភាពទូទៅនៃទំនាស់ដីធ្លីមកធ្វើការសិក្សា ក្នុងនោះរួមមានដូចជា បុព្វហេតុនៃការកើតឡើងនៃទំនាស់ដីធ្លី និងប្រភេទដីធ្លីដែលជាកម្មវត្ថុនៃទំនាស់ជាដើម។ ម្យ៉ាងវិញទៀត នៅផ្នែកខាងក្រោយនៃជំពូកនេះ នឹងបង្ហាញអំពីផលប៉ះពាល់សំខាន់ៗដែលកើតចេញពីទំនាស់ដីធ្លីចំពោះប្រជាពលរដ្ឋ ក៏ដូចជាសង្គមជាតិទាំងមូលផងដែរ។

## ២.១. ទិដ្ឋភាពទូទៅនៃទំនាស់ដីធ្លី

ចំពោះទិដ្ឋភាពទូទៅនេះ នឹងធ្វើការសិក្សាទៅលើកត្តាសំខាន់ៗដែលជាហេតុនាំឲ្យមានការកើតឡើងនៃទំនាស់ដីធ្លី ដែលមានដូចជា ការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ការគ្រប់គ្រងដីធ្លីគ្មានប្រសិទ្ធភាព និង ភាពមិនច្បាស់លាស់នៃបទប្បញ្ញត្តិច្បាប់ជាដើម (២.១.១)។ ម្យ៉ាងវិញទៀត

[68] ហ៊ែល ចំរើន, "ពិចារណាមួយលើវិវាទដីធ្លីនៅកម្ពុជា", *ស្សេបវត្តិ* (២០០៧), ៤៧។

[69] https://phalthy.files.wordpress.com/2006/11/w14-land-dispute-resolutions.pdf (ចូលទស្សនានៅថ្ងៃទី ៣ កក្កដា ២០១៥ )។

[70] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី, លេខ៤៧អនក្រ/បក, ៣១ ឧសភា ២០០២។

[71] ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, នស/រកត/០២០៦/០៩៧, ២៦ កុម្ភៈ ២០០៦។

នឹងលើកបង្ហាញ អំពីលក្ខណៈពិសេសនៃទំនាស់ដីធ្លីផងដែរ រួមមានដូចជា ប្រភេទដីធ្លីដែលងាយនឹងកើតមានទំនាស់ ដូចជាដីធ្លីដែលពុំទាន់កំណត់អត្តសញ្ញាណច្បាស់លាស់ជាដើម (២.១.២)។

### ២.១.១. កត្តាដែលបណ្តាលឲ្យមានទំនាស់ដីធ្លី

ទំនាស់ដីធ្លីកើតឡើងដោយសារកត្តាជាច្រើនយ៉ាងដែលរួមផ្សំបញ្ចូលគ្នា ក្នុងនោះមានដូចជា តម្លៃដីកើនឡើងខ្ពស់យ៉ាងគំហុក គួបផ្សំនឹងដីដែលមិនទាន់ចុះបញ្ជី ស្ថានភាពនៃការគោរព និងការអនុវត្តច្បាប់នៅធូររលុងមិនសូវតឹងរឹង និងការមិនទប់ស្កាត់តាំងពីដំបូងនូវការចូលកាន់កាប់ដីរដ្ឋដោយខុសច្បាប់ជាដើម។[72] បើពិនិត្យឲ្យច្បាស់លាស់នៃមូលហេតុខាងលើឃើញថា វាជាប់ពាក់ព័ន្ធយ៉ាងជិតស្និតទៅនឹងស្ថានភាពផ្ទាល់របស់តួអង្គសំខាន់ៗដែលដើរតួរនៅក្នុងការបង្កឲ្យមានទំនាស់ដីធ្លីនេះ។ ប្រសិនបើធ្វើការបែងចែកជាពួកធំៗ កត្តាសំខាន់ៗដែលបណ្តាលឲ្យមានទំនាស់ដីធ្លីមានពីរ គឺកត្តាដែលកើតចេញពីប្រជាពលរដ្ឋ (២.១.១.១) និងកត្តាដែលកើតចេញពីអាជ្ញាធរ (២.១.១.២)។

#### ២.១.១.១ កត្តាដែលកើតចេញប្រជាពលរដ្ឋ

កត្តាដែលកើតចេញពីប្រជាពលរដ្ឋ សំដៅទៅលើសកម្មភាពរបស់ប្រជាពលរដ្ឋដែលបានចូលកាន់កាប់ដីរដ្ឋ និងដីធ្លីឯកជនដោយខុសច្បាប់។ ហើយមូលហេតុដែលជំរុញឲ្យមានការទន្ទ្រានកាន់កាប់ដីធ្លីទាំងអស់នេះ មានដូចជា ភាពក្រីក្រ និងមូលហេតុមួយចំនួនទៀតដូចជាចំណេះដឹងជាដើម។

ភាពក្រីក្រ សំដៅលើប្រជាពលរដ្ឋក្រីក្រដែលខ្វះជម្រក និងដីធ្លីសម្រាប់ធ្វើកសិកម្មចិញ្ចឹមជិវិត [73] ហើយភាពក្រីក្រនេះ ត្រូវបានកំណត់ជាភាគរយនៃចំនួនប្រជាជនដែលចំណាយប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់ទាបជាងខ្សែបន្ទាត់នៃភាពក្រីក្រជាតិ។[74] ចាប់ពីឆ្នាំ២០០៤ ដល់២០០៧រដ្ឋាភិបាលបានកាត់បន្ថយភាពក្រីក្របាន ៥%ជាក់ស្តែងគឺ ពី៣៥%មកត្រឹម ៣០%។[75] ហើយអត្រាភាពក្រីក្រនៅតាមជនបទក្នុងឆ្នាំ២០០៧បានកាត់បន្ថយពី ៥៣%មកសល់ប្រហែលជា ២១%នៅក្នុងឆ្នាំ

---

[72] ប៊ិន ឈិន, *របាយការណ៍ និងសកម្មភាពការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីឆ្នាំ២០០៩*, លេខ០៣/១០ របក/អជដ (ភ្នំពេញ៖ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, ១៧ កុម្ភៈ ២០១០) ១។

[73] បទអន្តរាគមន៍របស់អភិបាលរង នៃគណៈអភិបាលខេត្តព្រះសីហនុក្នុងពិធីបើកសន្និបាត បូកសរុបលទ្ធផលការងារឆ្នាំ២០០៩ និងទិសដៅបន្តការងារឆ្នាំ២០១០ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី នាថ្ងៃទី ២៧ មករា ២០១០។

[74] ឆាយ ថន, *ការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា៖ បច្ចុប្បន្នភាព ឆ្នាំ២០១០* (ភ្នំពេញ៖ ក្រសួងផែនការ, មីនា ២០១១) ១០, http://www.mop.gov.kh/Home/CMDGs/tabid/156/Default.aspx (ថតចម្លងថ្ងៃទី ០៧ កក្កដា ២០១៥)។

[75] ឆាយ ថន, *ការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា៖ បច្ចុប្បន្នភាព ឆ្នាំ២០១០* (ភ្នំពេញ៖ ក្រសួងផែនការ, មីនា ២០១១) ១១, http://www.mop.gov.kh/Home/CMDGs/tabid/156/Default.aspx (ថតចម្លងថ្ងៃទី ០៧ កក្កដា ២០១៥)។

២០១១។[76] ទោះបីជាអត្រានៃភាពក្រីក្រមានការធ្លាក់ចុះក៏ដោយ ប៉ុន្តែអត្រាភាពក្រីក្រនៅកម្ពុជានៅតែស្ថិតក្នុងអត្រាខ្ពស់នៅឡើយ បើធៀបទៅនឹងបណ្តាប្រទេសក្នុងតំបន់ ដូចជា វៀតណាម ម៉ាឡេស៊ី ហ្វីលីពីនជាដើម។[77] ក្នុងចំណោមប្រជាពលរដ្ឋក្រីក្រទាំងអស់នេះ មានប្រហែលជា១២% ជាប្រជាពលរដ្ឋដែលមិនមានដីធ្លី[78] ហើយភាគរយនេះនឹងកាន់តែកើនឡើងថែមទៀត ដោយសារតែកំណើនប្រជាជន និងការកែប្រែសេដ្ឋកិច្ចពីការពឹងផ្អែកលើវិស័យកសិកម្ម ទៅជាឧស្សាហកម្ម និងសេវាកម្ម ដោយពុំមានគោលនយោបាយច្បាស់លាស់។[79]

ភាពក្រីក្រ និងភាពគ្មានដីធ្លីសម្រាប់សង់លំនៅដ្ឋាន និងសម្រាប់ធ្វើកសិកម្មចិញ្ចឹមគ្រួសារ បាននិងកំពុងក្លាយទៅជាកត្តាចម្បងដែលជំរុញឲ្យ ប្រជាពលរដ្ឋចូលទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់។ គួរកត់សម្គាល់ដែរថា ប្រជាពលរដ្ឋដែលស្ថិតនៅក្រោមបន្ទាត់ក្រីក្រនេះ ភាគច្រើនស្ថិតក្នុងខេត្ត ព្រះវិហារ រតនៈគិរី ស្ទឹងត្រែង ក្រចេះ និងមណ្ឌលគិរី[80] ដែលសុទ្ធសឹងតែជាខេត្តសំបូរព្រៃឈើជាងគេក្នុងប្រទេសកម្ពុជា។[81] ហើយខេត្តផ្សេងដទៃទៀតដូចជា កំពង់ចាម បាត់ដំបង និងកំពង់ស្ពឺជាដើមមានព្រៃឈើជាមធ្យម។ តាមរយៈស្ថានភាពភូមិសាស្ត្រដែលសំបូរដីព្រៃ រួមផ្សំជាមួយភាពក្រីក្រ លទ្ធភាពដែលជំរុញឲ្យប្រជាពលរដ្ឋចូលកាន់កាប់ដីគឺមានកាន់តែខ្ពស់គួរឲ្យកត់សម្គាល់។ ជាក់ស្តែង នៅក្នុងខេត្តព្រះសីហនុ មានទំនាស់ដីធ្លីដែលកើតឡើងដោយសារការចូលកាន់កាប់ដីសាធារណៈរបស់រដ្ឋ ហើយអ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺ ដីព្រៃជាង៥០%សុទ្ធសឹងតែមានប័ណ្ណកម្មសិទ្ធិ។[82] លើសពីនេះ ដីព្រៃឈើចំនួន៥០៧.១០៦ហិកតា ត្រូវបានបង្ហាញថា កើតមានទំនាស់ដីធ្លីដោយសារ

---

[76] ហ៊ុន សែន, *របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៣ស្តីពីការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* (ភ្នំពេញ៖ ក្រសួងផែនការ, ១១ មេសា ២០១៤), ៧, http://www.mop.gov.kh/Home/CMDGs/tabid/156/Default.aspx (ថតចម្លងថ្ងៃទី ០៨ កក្កដា ២០១៥)។

[77] Word Food Programme, "Poverty: Cambodia" [ភាពក្រីក្រ៖ ប្រទេសកម្ពុជា], http://www.foodsecurityatlas.org/khm/country/access/poverty (ចូលទស្សនាថ្ងៃទី ០៨ កក្កដា ២០១៥)។

[78] Rural Poverty Portal, *Rural Poverty in Cambodia* [ភាពក្រីក្រនៃជនបទនៅកម្ពុជា], http://www.ruralpovertyportal.org/country/home/tags/cambodia (ចូលទស្សនាថ្ងៃទី ០៨ កក្កដា ២០១៥)។

[79] សមាគមអាដហុក (ADHOC), *ផ្លូវបត់?៖ សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា* (ភ្នំពេញ៖ សមាគមអាដហុក, ២៣ កុម្ភៈ ២០១៣), ២៨។

[80] ឆាយ ថន, *ការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា៖ បច្ចុប្បន្នភាព ឆ្នាំ២០១០* (ភ្នំពេញ៖ ក្រសួងផែនការ, មីនា ២០១១) ១២, http://www.mop.gov.kh/Home/CMDGs/tabid/156/Default.aspx (ថតចម្លងថ្ងៃទី ០៧ កក្កដា ២០១៥)។

[81] ឥន្ទ ឱមសាម៉េង និងផ្សេងទៀត, *ភូមិវិទ្យាសេដ្ឋកិច្ច និងមនុស្សនៃប្រទេសកម្ពុជា* (ភ្នំពេញ៖ ជោគជ័យ, ២០១២-២០១៣), ១៩៩។

[82] បទអន្តរាគមន៍របស់ឯកឧត្តមអភិបាលរង នៃគណៈអភិបាលខេត្តព្រះសីហនុក្នុងពិធីបើកសន្និបាត បូកសរុបលទ្ធផលការងារឆ្នាំ ២០០៩ និងទិសដៅបន្តការងារឆ្នាំ ២០១០ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដី។

ការទន្ទ្រានចូលកាន់កាប់។[83] គួរបញ្ជាក់ដែរថា ទាក់ទងនឹងបញ្ហាការកាន់កាប់ដីរដ្ឋដោយខុសច្បាប់នេះ បើគិតចាប់ពីឆ្នាំ១៩៩២ រហូតមកដល់ឆ្នាំ២០០៧ រាជរដ្ឋាភិបាលបានចេញលិខិតបទដ្ឋានគតិយុត្តយ៉ាងហោចណាស់ចំនួន១៣[84]ហើយ ការណ៍បង្ហាញថា សកម្មភាពនៃការចូលកាន់កាប់ដីរដ្ឋគឺស្ថិតនៅក្នុងបញ្ហាគួរឲ្យព្រួយបារម្ភ។ ដូចនេះ តាមរយៈការបង្ហាញខាងលើ អាចបញ្ជាក់បានថា ភាពក្រីក្រ និងភាពគ្មានដីធ្លីអាចជាមូលហេតុជំរុញឲ្យប្រជាពលរដ្ឋក្រីក្រដែលគ្មានដីធ្លី ចូលកាន់កាប់ដីរដ្ឋដោយខុសច្បាប់ស្ទើរគ្រប់ទីកន្លែង ហើយសកម្មភាពចូលកាន់កាប់ដីរដ្ឋដោយខុសច្បាប់នេះ ជាមូលហេតុនាំឲ្យកើតមានទំនាស់ដីធ្លី។ មូលហេតុដែលនាំឲ្យកើតមានទំនាស់ដីធ្លីនេះ មិនមែនដោយសារតែប្រជាពលរដ្ឋចូលកាន់កាប់ដីរដ្ឋតែមួយមុខគត់នោះទេ តែវាគួបផ្សំទៅនឹងភាពធ្វេសប្រហែសក្នុងការគ្រប់គ្រងដីធ្លី ឬអាចនិយាយបានមួយបែបទៀតថា ទំនាស់ដីធ្លីកើតចេញពីអាជ្ញាធរ។

### ២.១.១.២. កត្តាដែលកើតចេញពីអាជ្ញាធរ

កត្តាដែលកើតចេញពីអាជ្ញាធរនេះ សំដៅទៅលើឥរិយាបថ ឬសកម្មភាពរបស់មន្ត្រីរាជការដែលអនុវត្តការងារទាក់ទងនឹងការគ្រប់គ្រង បែងចែកដីធ្លីដែលមិនប្រកបដោយប្រសិទ្ធភាព ដែលនាំឲ្យក្លាយជាចលករផ្សេងៗ ហើយជំរុញឲ្យកើតមានទំនាស់ដីធ្លីនេះឡើង។ សកម្មភាពការងាររបស់អាជ្ញាធរ ក៏ដូចជាមន្ត្រីរាជរដ្ឋាភិបាលដែលកំពុងអនុវត្តលើវិស័យដីធ្លីជួយអនុគ្រោះ និងផ្តល់អាទិភាព

[83] បទអន្តរាគមន៍របស់អគ្គលេខាធិការរង នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីក្នុងពិធីបើកសន្និបាត បូកសរុបលទ្ធផលការងារឆ្នាំ ២០០៩ និងទិសដៅបន្តការងារឆ្នាំ ២០១០ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។

[84] សារាចរណែនាំស្តីពីវិធានការចំពោះសកម្មភាពរំលោភយកដីសាធារណៈ, លេខ០៣សរណន, ១៩ ធ្នូ ១៩៩២។; សារាចរស្តីពីកម្មសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋបច្ចុប្បន្ន និងកម្មសិទ្ធិសាធារណៈ, លេខ០១សរ, ០៣ កក្កដា ១៩៩៣។; លិខិតរបស់សម្តេចនាយករដ្ឋមន្ត្រីទី១ផ្ញើជូនសម្តេចនាយករដ្ឋមន្ត្រីទី២ស្នើឲ្យការសុំកាន់កាប់ដីធ្លីឆ្លងកាត់ទីស្តីការគណៈរដ្ឋមន្ត្រី, លេខ៩១៨ខុទ្ទ/៩៥, ១៦ មិថុនា ១៩៩៥។; លិខិតរបស់គណៈរដ្ឋមន្ត្រីស្តីពីករណីបញ្ហាទំនាស់កម្មសិទ្ធិដីធ្លីរវាងអាជ្ញាធរ និងប្រជារាស្ត្រ, លេខ១០៥២សជណ/សរ, ០៥ កក្កដា ១៩៩៥។; លិខិតរបស់ក្រសួងបរិស្ថានស្តីពីបញ្ហាកម្មសិទ្ធិដីធ្លីក្នុងតំបន់ការពារធម្មជាតិ, លេខ១៧១៩បស្ត, ១៩ កញ្ញា ១៩៩៥។; សេចក្តីប្រកាសស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអានាធិបតេយ្យក្នុងវិស័យព្រៃឈើ, លេខ០១ប្រក, ២៥ មករា ១៩៩៩។; សេចក្តីប្រកាសស្តីពីវិធានការលុបបំបាត់ភាពអានាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់ដីធ្លី, លេខ០៦ប្រក, ២៧ កញ្ញា ១៩៩៩។; បទបញ្ជាស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រានការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ, លេខ០១បប, ០៩ មិថុនា ២០០៤។; សេចក្តីណែនាំអនុវត្តបទបញ្ជាស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ, លេខ៦២៣ដនស/សជ, ១៦ មិថុនា ២០០៤។; បទបញ្ជាស្តីពីការទប់ស្កាត់ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកមកធ្វើជាកម្មសិទ្ធិ, លេខ០១បប, ១០ ឧសភា ២០០៦។; សេចក្តីជូនដំណឹងស្តីពីការផ្អាកជាបណ្តោះអាសន្ននូវការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលើដីព្រៃឈើគ្រប់ប្រភេទ, លេខ០៩សជណ/សជ, ០៤ កក្កដា ២០០៦។; សេចក្តីណែនាំស្តីពីវិធានការទប់ស្កាត់ការកាប់រានដីព្រៃឈើ និងការចេញលិខិតបញ្ជាក់ការទិញលក់ដីក្នុងតំបន់ការពារធម្មជាតិ, លេខ០០១សណន, ០៩ មករា ២០០៧។; សារាចរស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់, លេខ០២សរ, ២៦ កុម្ភៈ ២០០៧។

យ៉ាងខ្លាំងក្នុងការជំរុញឲ្យកើតមានទំនាស់ដីធ្លី។ កត្តាជំរុញឲ្យកើតមានទំនាស់ដីធ្លីនេះ រួមមានភាពយឺតយ៉ាវចំពោះកម្មសិទ្ធិលើដីធ្លី និងការផ្តល់សម្បទានដីសេដ្ឋកិច្ចដោយកង្វះការពិភាក្សា និងការវាយតម្លៃ។

ដូចបានបង្ហាញនៅជំពូកទី១ គិតត្រឹមឆ្នាំ២០១៣ មានប្រហែលជាង ៣លានក្បាលដីដែលត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធិ។ ទិន្នន័យនេះ បើធៀបទៅនឹងចំនួនក្បាលដីសរុប ដីធ្លីបានចុះបញ្ជីមានប្រហែលជា ៣០%តែប៉ុណ្ណោះ (១០លានក្បាលដី[85]) ខណៈពេលដែលដីធ្លីដល់ច្រើនលើសលប់ផ្សេងទៀតកំពុងទន្ទឹងរង់ចាំការចុះបញ្ជី។[86] ការណ៍នេះ នាំឲ្យកើតមានអសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ហើយដីធ្លីទាំងអស់នេះងាយនឹងរងគ្រោះបានគ្រប់ពេលវេលា។[87]

"សម្បទានដីសេដ្ឋកិច្ច សំដៅដល់យន្តការសម្រាប់ផ្តល់ដីឯកជនរបស់រដ្ឋ តាមរយៈកិច្ចសន្យាសម្បទានមួយជាក់លាក់ទៅឲ្យសម្បទានិក ដើម្បីប្រើប្រាស់សម្រាប់ធ្វើអាជីវកម្ម កសិកម្ម និងកសិ-ឧស្សាហកម្ម។" [88] ការផ្តួចផ្តើមគម្រោងសម្បទានដីសេដ្ឋកិច្ចត្រូវបានធ្វើឡើងតាមរូបភាពពីរយ៉ាង ទី១ សំណើមានការអំពាវនាវ[89]ដែលអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាជាអ្នកលើកគម្រោងដើម្បីអំពាវនាវឲ្យអ្នកវិនិយោគដាក់សំណើ ហើយទី២ សំណើមិនមានការអំពាវនាវ[90]ដែលអ្នកវិនិយោគជាអ្នកលើកគម្រោងស្នើទៅរដ្ឋ ដើម្បីសុំការអនុញ្ញាត។[91] ហើយល័ក្ខខ័ណ្ឌទូទៅក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចនេះគឺមានកំណត់យ៉ាងច្បាស់ក្នុងមាត្រា៤ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច។ ប៉ុន្តែការចំពោះការអនុវត្តជាក់ស្តែង សម្បទានដីសេដ្ឋកិច្ចត្រូវបានគេរកឃើញថា មានករណីជាច្រើនដែលការផ្តល់សម្បទានដីសេដ្ឋកិច្ច មិនបានអនុវត្តឲ្យបានពេញលេញតាមច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុក្រឹត្យលេខ១៤៦ស្តីពីសម្បទានដីសេដ្ឋកិច្ច។[92] ជាពិសេស កង្វះការពិភាក្សា និងការវាយតំម្លៃ

[85] Hap Phalthy, "The Implementation of Cambodia's Laws on Land Tenure"[ការអនុវត្តច្បាប់កម្ពុជាលើការកាន់កាប់ដីធ្លី], Cambodian Yearbook of Comparative Legal Studies Vol.2 (2011): 190។

[86] ហ៊ែល ចំរើន, "ពិចារណាមួយលើវិវាទដីធ្លីនៅកម្ពុជា", វស្សបវត្តិ (២០០៧), ៦២។

[87] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, *ដីមានជម្លោះ ទិដ្ឋភាពនៃស្ថានភាពដីធ្លី* (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ធ្នូ ២០១៣), ២១ និង ២២។

[88] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច, លេខ១៤៦អនក្រ/បក, ២៧ ធ្នូ ២០០៥, មាត្រា២។

[89] សំណើមានការអំពាវនាវមានន័យថា រដ្ឋបានត្រៀមខ្លួន និងរៀបចំទុកជាមុនទាក់ទងនឹងស្ថានភាពដី មុននឹងផ្តល់សម្បទាន, https://phalthy.files.wordpress.com/2006/11/w12-economic-land-concessions.pdf។

[90] សំណើមិនមានការអំពាវនាវមានន័យថា រដ្ឋមិនបានតៀមខ្លួន និងរៀបចំទុកជាមុនឡើយក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ច, https://phalthy.files.wordpress.com/2006/11/w12-economic-land-concessions.pdf។

[91] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច, លេខ១៤៦អនក្រ/បក, ២៧ ធ្នូ ២០០៥, មាត្រា៦។

[92] សមាគមអាដហុក (ADHOC), *របាយការណ៍ សិទ្ធិដីធ្លី និងលំនៅដ្ឋាន ឆ្នាំ២០១១* (ភ្នំពេញ៖ សមាគមអាដហុក, មីនា ២០១២), ១៩។

អំពីផលប៉ះពាល់ [93] ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ធ្វើសម្បទានដីសេដ្ឋកិច្ចពុំបានដឹងអំពីការធ្វើសម្បទាននោះទេ ដែលនេះសុទ្ធសឹងតែជាលក្ខខ័ណ្ឌចាំបាច់ក្នុងការផ្ដល់ដីសម្បទាន។ ជាក់ស្ដែង ភូមិកាំ ក្នុងខេត្តរតនគិរី ក្រុមជនជាតិដើមភាគតិច និងសូម្បីតែអាជ្ញាធរមូលដ្ឋានមិនបានដឹងទាល់តែសោះថា មានក្រុមហ៊ុនបានទទួលសម្បទានដីសេដ្ឋកិច្ចនៅលើដីដែលពួកគេកំពុងប្រើប្រាស់[94] លុះដល់ពេលកម្មករក្រុមហ៊ុនបានមកដល់ ហើយចាប់ផ្ដើមឈូសឆាយដីរបស់ពួកទើបពួកគេបានដឹង។ ហើយករណីបែបនេះ មានស្ទើរគ្រប់ទីកន្លែងនៅទូទាំងប្រទេស។ ដូចនេះ តាមរយៈការអនុវត្តការងាររបស់មន្ត្រីរាជការដែលបានផ្ដល់សម្បទានដីសេដ្ឋកិច្ច ដោយខ្វះការពិភាក្សា និងវាយតម្លៃលើផលប៉ះពាល់នេះ អាចជាកត្តាជំរុញឲ្យទំនាស់ដីធ្លីកើតមានឡើង។

### ២.១.២. លក្ខណៈពិសេសនៃទំនាស់ដីធ្លី

នៅក្នុងចំណុចនេះ លើកបង្ហាញអំពីប្រភេទដីធ្លីដែលជាកម្មវត្ថុងាយនឹងកើតមានទំនាស់ដែលក្នុងនោះ មិនថាដីធ្លីនៅទីប្រជុំជន ឬដីធ្លីនៅតាមជនបទទេ ឲ្យតែមិនទាន់ទទួលបានការចុះបញ្ជីសុរិយោដីសុទ្ធសឹងតែជាប្រភេទដីដែលជាកម្មវត្ថុងាយនឹងបង្កឲ្យមានទំនាស់ដីធ្លីទាំងអស់។

#### ២.១.២.១. ប្រភេទដីដែលជាកម្មវត្ថុនៃទំនាស់

ដីធ្លីដែលជាកម្មវត្ថុនៃទំនាស់ មានលក្ខណៈខុសប្លែកពីគ្នាទៅតាមតំបន់ និងតាមស្ថានភាពផ្សេងៗគ្នា។ មកដល់ពេលនេះ មិនមានការស្រាវជ្រាវ ឬទិន្នន័យផ្លូវការណាមួយដែលបញ្ជាក់អំពីប្រភេទដីធ្លីដែលងាយប្រឈមនឹងការកើតទំនាស់ឲ្យបានច្បាស់លាស់នៅឡើយទេ។ តែទោះជាយ៉ាងណាក៏ដោយតាមរយៈប្រភពផ្សេងៗទាក់ទងនឹងដីធ្លីដែលមានទំនាស់ អាចឲ្យកំណត់បានអំពីប្រភេទដីដែលងាយនឹងកើតមានទំនាស់បាន នោះគឺដីដែលមិនទាន់ចុះបញ្ជីជាមួយដីធ្លីដែលជាប់ទាក់ទងនឹងការផ្ដល់សម្បទានដីសេដ្ឋកិច្ច។

ដីធ្លីដែលត្រូវបានចុះបញ្ជីសុរិយោដី ហើយទទួលបានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ និងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ គឺសុទ្ធសឹងតែត្រូវបានទទួលការគាំពារដោយច្បាប់យ៉ាងពេញលេញ។ នេះដោយសារតែ តម្លៃគតិយុត្តនៃលិខិតផ្លូវការបានចេញដោយអាជ្ញាធរមានសមត្ថកិច្ច។[95]

[93] អនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច, លេខ១៤៦អនក្រ/បក, ២៧ ធ្នូ ២០០៥, មាត្រា៣ ចំនុច៣និង៥។; មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR), *ដីមានជម្លោះ ទិដ្ឋភាពនៃស្ថានភាពដីធ្លី* (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ធ្នូ ២០១៣), ២៩និង៣០។

[94] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR), *ដីមានជម្លោះ ទិដ្ឋភាពនៃស្ថានភាពដីធ្លី* (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ធ្នូ ២០១៣), ៣១។

[95] ហៃល ចំរើន, "ពិចារណាមួយលើវិវាទដីធ្លីនៅកម្ពុជា", វស្សបវត្តិ (២០០៧), ៥៩និង៦២។

ផ្ទុយមកវិញ ដីធ្លីដែលពុំទាន់មានប័ណ្ណដ៏ច្រើនលើសលប់ ពុំត្រូវបានច្បាប់ការពារឡើយ ហើយកំពុងតែក្លាយជាកម្មវត្ថុនៃទំនាស់ដីធ្លីយ៉ាងសកម្ម នៅពេលដែលដីធ្លីទាំងអស់នោះត្រូវបានផ្តល់ជាលក្ខណៈសម្បទានដីសេដ្ឋកិច្ច។ ការកាន់កាប់ដីធ្លីតាមលក្ខណៈប្រពៃណី ដោយឥតមានចុះបញ្ជីដីធ្លី ព្រោះអ្នកកាន់កាប់គ្មានលទ្ធភាពនឹងចុះក្តី ឬព្រោះក្រសួងសមត្ថកិច្ចពុំទាន់ចុះបញ្ជីក្តី ដីធ្លីទាំងអស់នោះត្រូវបានទុកឲ្យនៅក្រៅកិច្ចគាំពារនៃច្បាប់ និងអាចទទួលរងនូវការរំលោភបំពានយ៉ាងងាយស្រួល ខណៈពេលដែលស្ថិតក្នុងស្ថានភាពអស្ថិរភាព និងអសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី។[96] ជាក់ស្តែង នៅខែមករា ក្រុមជនជាតិភាគតិចរាប់រយនាក់រស់នៅខេត្តព្រះវិហារកើតមានទំនាស់ដីធ្លីជាមួយក្រុមហ៊ុនដែលទទួលបានអាជ្ញារប័ណ្ណសម្បទានដីសេដ្ឋកិច្ច។[97]

## ២.២. ផលប៉ះពាល់ដែលកើតចេញពីទំនាស់ដីធ្លី

ទំនាស់ដីធ្លីបានបង្កឲ្យមានឥទ្ធិពលអាក្រក់យ៉ាងខ្លាំង ចំពោះមជ្ឈដ្ឋានជុំវិញដែលទាក់ទងនឹងការប្រើប្រាស់ដីធ្លី ដូចជាដីកសិកម្ម ដីលំនៅដ្ឋានជាដើម។ ក្នុងផ្នែកនេះ នឹងលើកឡើងអំពីទិដ្ឋភាពរួមនៃផលប៉ះពាល់ដែលកើតមានចំពោះប្រជាពលរដ្ឋ (២.២.១) និងផលប៉ះពាល់ចំពោះសង្គមជាតិទាំងមូល (២.២.២)។

### ២.២.១. ផលប៉ះពាល់ចំពោះប្រជាពលរដ្ឋ

ប្រជាពលរដ្ឋដែលកំពុងរស់នៅ និងធ្វើការដាំដុះលើដីមានទំនាស់ អាចប្រឈមនឹងបញ្ហាយ៉ាងធ្ងន់ធ្ងរដែលកើតចេញពីដីមានទំនាស់នោះ។ បញ្ហាធ្ងន់ធ្ងរនេះគឺ ការប្រឈមនឹងការបាត់បង់ដីធ្លីទាំងដីលំនៅដ្ឋាន និងដីកសិកម្ម។

#### ២.២.១.១. ការបាត់បង់ដីធ្លីដែលកំពុងកាន់កាប់

នៅសម័យកម្ពុជាប្រជាធិបតេយ្យកម្មសិទ្ធិឯកជនទាំងអស់ត្រូវបានរំលាយ ហើយមកដល់បច្ចុប្បន្ននេះ ប្រជាពលរដ្ឋភាគច្រើនដែលរស់នៅជនបទ នៅតែផ្អែកលើការតាំងលំនៅ និងអាស្រ័យផលលើដីកសិកម្ម ដោយពួកគេគិតថានេះជាល័ក្ខខ័ណ្ឌគ្រប់គ្រាន់ហើយក្នុងការសម្គាល់ជាម្ចាស់កម្មសិទ្ធិដីធ្លី ប៉ុន្តែ ប្រជាពលរដ្ឋរាប់លាននាក់នេះនៅតែខ្វះឯកសារ និងការទទួលស្គាល់យ៉ាងពេញលេញលើសិទ្ធិពួកគេដែលអមជាមួយនឹងកម្មសិទ្ធិដីធ្លី។ [98] ការណ៍នេះ នាំឲ្យប្រជាពលរដ្ឋត្រូវបានរងការ

[96] ហៃាល ចំរើន, "ពិចារណាមួយលើវិវាទដីធ្លីនៅកម្ពុជា", វស្សបវត្តិ (២០០៧), ៦៣។

[97] លីកាដូ (LICADHO), *ឆ្នាំ២០១៤ នាំមកនូវរលកថ្មីនៃជម្លោះដីធ្លីនៅកម្ពុជា* (ភ្នំពេញ៖ លីកាដូ), ១។

[98] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR), *ដីមានជម្លោះ ទិដ្ឋភាពនៃស្ថានភាពដីធ្លី* (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ធ្នូ ២០១៣), ២១។

បណ្តេញចេញដោយបង្ខំ ហើយបាត់បង់ដីធ្លីរបស់ពួកគេដែលធ្លាប់ប្រើប្រាស់ នៅពេលក្រុមហ៊ុនបានទទួលសិទ្ធិសម្បទានដីសេដ្ឋកិច្ច។[99] តាមរយៈការបាត់បង់ដីធ្លី ហើយត្រូវបានបណ្តេញចេញដោយបង្ខំទៀតនេះ "មិនមែនប៉ះពាល់មកលើតែផ្ទះរបស់នរណាម្នាក់នោះទេ។ ជាញឹកញយ ការបណ្តេញចេញនេះនឹងបណ្តាលឲ្យមានកំណើនភាពក្រីក្រកើនឡើង ការទទួលបានប្រាក់ចំណូលមានកម្រិតបំណុល កង្វះទឹកស្អាតប្រើប្រាស់និងអនាម័យ និងជីវភាពរស់នៅប្រចាំថ្ងៃ បញ្ហាសុខភាពរាងកាយ និងសុខភាពផ្លូវចិត្តធ្វើឲ្យក្រុមគ្រួសារបែកបាក់ ការរើសអើងក្នុងសង្គម ភាពបែកបាក់សាមគ្គីក្នុងសហគមន៍ និងបន្តក្លាយជាជនដែលត្រូវបានគេចាត់ឲ្យនៅក្រៅសង្គម។"[100] ជាក់ស្តែង ប្រាក់ចំណូលប្រចាំឆ្នាំរបស់ប្រជាពលរដ្ឋរងគ្រោះពីការបណ្តេញចេញក្នុងភូមិព្រែកជីក ខេត្តកោះកុងមានការធ្លាក់ចុះពី២,០៧០.៣១ដុល្លាមកត្រឹម ៣១៥.៨៩ដុល្លា។[101] នេះមានន័យថា ប្រជាពលរដ្ឋរងគ្រោះពីការបណ្តេញចេញនេះត្រូវបានបាត់បង់ចំណូលប្រចាំឆ្នាំប្រមាណជា ១,៧០០ដុល្លា។

### ២.២.២. ផលប៉ះពាល់ចំពោះសង្គមជាតិទាំងមូល

ផលប៉ះពាល់ចំពោះសង្គមជាតិនេះ រួមមានផលប៉ះពាល់លើសង្គមសេដ្ឋកិច្ច រាំងស្ទះដល់ដំណើរការអភិវឌ្ឍនសង្គមជាតិ (២.២.២.១) និងផលប៉ះពាល់ទៅលើសិទ្ធិមនុស្ស ដោយមានការរំលោភបំពានលើសិទ្ធិលំនៅដ្ឋាន និងសិទ្ធិដីធ្លី (២.២.២.១)។

#### ២.២.២.១. ផលប៉ះពាល់លើសង្គម និងសេដ្ឋកិច្ច

ទំនាស់ដីធ្លីនៅកម្ពុជា បានធ្វើឲ្យប៉ះពាល់ដល់សង្គម និងផលប៉ះពាល់ដល់សេដ្ឋកិច្ចដូចជាបង្កឲ្យមានវិបត្តិសង្គម ដែលនាំធ្វើឲ្យប្រជាពលរដ្ឋទឹកភ្នែកស្ទើរគ្រប់ទីកន្លែងដោយសារការបាត់បង់ដីធ្លី និង ផលប៉ះពាល់ដល់ការអភិវឌ្ឍខាងវិស័យសេដ្ឋកិច្ច។

ដូចដែលបានដឹងរួចមកហើយ ទំនាស់ដីធ្លីភាគច្រើនតែងតែកើតនៅលើដីធ្លីដែលពុំទាន់បានចុះបញ្ជីរវាងក្រុមប្រជាពលរដ្ឋជាមួយក្រុមហ៊ុន ដែលបានទទួលដីសម្បទានសេដ្ឋកិច្ចលើដីធ្លីទាំងនោះ។ ជាទូទៅ ក្រុមហ៊ុនដែលទទួលបានដីសម្បទានសេដ្ឋកិច្ចតែងតែធ្វើការឈូសឆាយលើដីធ្លីដើម្បីអនុវត្តផែនការការងារស្របតាមគោលបំណងនៃសម្បទានដី ទោះបីជាដីធ្លីនោះមានប្រជាពលរដ្ឋ

[99] សមាគមអាដហុក (ADHOC), *របាយការណ៍ សិទ្ធិដីធ្លី និងលំនៅដ្ឋាន ឆ្នាំ២០១១* (ភ្នំពេញ៖ សមាគមអាដហុក, មីនា ២០១២), ២៥។

[100] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR), *ដីមានជម្លោះ ទិដ្ឋភាពនៃស្ថានភាពដីធ្លី* (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ធ្នូ ២០១៣), ៩៣។

[101] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR), *ដីមានជម្លោះ ទិដ្ឋភាពនៃស្ថានភាពដីធ្លី* (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ធ្នូ ២០១៣), ៩៥។

តាំងទីលំនៅ និងកំពុងបង្កបង្កើនក៏ដោយ។ តាមរយៈទង្វើនេះ បានធ្វើឲ្យលំនៅដ្ឋាន ដីកសិកម្ម និង ផលដំណាំរបស់ប្រជាពលរដ្ឋទទួលរងនូវការបំផ្លិចបំផ្លាញយ៉ាងតំណំ ហើយនាំឲ្យប្រជាពលរដ្ឋធ្វើការតវ៉ាតាមទាមយកដីធ្លីរបស់ពួកគេមកវិញ។ ជាក់ស្តែង នៅដើមខែមិថុនា សហគមន៍ទំនាស់ដីធ្លីមកពីស្រុកចំនួន៧ ស្ថិតក្នុងខេត្តព្រះវិហារបានលើកគ្នាទៅប្រមូលផ្តុំបំណងតវ៉ាជាទ្រង់ទ្រាយធំនៅក្នុងទីរួមខេត្តព្រះវិហារ ក៏ប៉ុន្តែមានតែសហគមន៍ទំនាស់ធ្លីប្រមាណ ៣០០នាក់ប៉ុណ្ណោះ ដែលចូលទៅដល់ទីរួមខេត្តព្រះវិហារ ដោយសារតែប៉ូលីសបានវាយបណ្តាក់កម្លាំងរាំងលើដងផ្លូវជាច្រើនកំណាត់មិនឲ្យអ្នកដំណើរចូលទៅកាន់ទីរួមខេត្តបាន។ [102] ករណីឡើងតវ៉ាបែបនេះមិនមែនមានតែក្នុងខេត្តព្រះវិហារទេ គឺមានគ្រប់ទីកន្លែងឲ្យតែមានជម្លោះដីធ្លី។ តាមរយៈការតវ៉ា និងសុំកិច្ចអន្តាគមន៍ពីស្ថាប័នរដ្ឋនេះ បានបង្ហាញយ៉ាងច្បាស់ថា សង្គមកំពុងជួបនឹងវិបត្តិដោយសារទំនាស់ដីធ្លី។អ្វីដែលធ្ងន់ធ្ងរជាងនេះគឺ ទំនាស់ដីធ្លីបានរាំងស្ទះដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដែលនេះជាវិស័យអាទិភាពចម្បងសម្រាប់កម្ពុជា ខណៈកម្ពុជាកំពុងស្ថិតក្នុងចំណាត់ថ្នាក់ប្រទេសមួយដែលមានការអភិវឌ្ឍតិចតួច។

### ២.២.២.២. ផលប៉ះពាល់ដល់សិទ្ធិមនុស្ស

ទំនាស់ដីធ្លីនេះ បានបង្កជាវិវាទរវាងក្រុមហ៊ុនដែលទទួលបានដីសម្បទានសេដ្ឋកិច្ច ជាមួយនិងប្រជាពលរដ្ឋដែលកំពុងកាន់កាប់ នៅពេលដែលដីធ្លីទាំងនោះត្រូវបានផ្តល់ជាសម្បទានដីសេដ្ឋកិច្ច។ ក្រោយពេលក្រុមហ៊ុនបានទទួលសិទ្ធិសម្បទានដីសេដ្ឋកិច្ច អាជ្ញាធរមានសមត្ថកិច្ចតែងតែចាត់វិធានការផ្សេងៗនៅលើដីធ្លី ហើយវិធានការនេះពេលខ្លះឈានទៅដល់ការបណ្តេញចេញទៀតផង។ ការចាត់វិធានការបែបនេះ ធ្វើឡើងដើម្បីការពារផលប្រយោជន៍របស់សម្បទាននិកដែលបានទទួលសិទ្ធិសម្បទានដីសេដ្ឋកិច្ច។ នេះដោយសារតែ ក្រុមហ៊ុនដែលជាសម្បទាននិកត្រូវបានគេទទួលស្គាល់ដូចជាកម្មសិទ្ធិករដែរ លើកលែងតែការផ្ទេរសិទ្ធិតែប៉ុណ្ណោះ។[103] នៅពេលមានហេតុការណ៍នៃការបណ្តេញចេញ ក្នុងករណីខ្លះមានអំពើហិង្សាកើតឡើងអមជាមួយ[104] នៅពេលនោះវាបានធ្វើឲ្យមានការលើកឡើងអំពីបញ្ហានៃការរំលោភសិទ្ធិមនុស្ស។ ជាពិសេស ករណីដែលអាជ្ញាធរ ឬក្រុមហ៊ុនវិនិយោគនានាបានធ្វើឲ្យប៉ះពាល់ដល់ដីធ្លី និងទ្រព្យសម្បត្តិឯកជនផ្សេងទៀតរបស់ប្រជាពលរដ្ឋ។

---

[102] ហង្ស សារយុត, "ពលរដ្ឋនៅព្រះវិហារខ្វះដីធ្វើស្រែរដូវវស្សាដោយសារជម្លោះដីជាមួយក្រុមហ៊ុន", (វិទ្យុអាស៊ីសេរី, ផ្សាយថ្ងៃទី១៥ មិថុនា ២០១៥), http://www.rfa.org/khmer/news/land/preah-vihear-06152015050445.html (ចូលទស្សនាថ្ងៃទី១២ កក្កដា ២០១៥)។

[103] ច្បាប់ភូមិបាល, នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៥៦។

[104] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR), *ដីមានជម្លោះ ទិដ្ឋភាពនៃស្ថានភាពដីធ្លី* (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ធ្នូ ២០១៣), ៣៤។

ចំពោះបញ្ហាសិទ្ធិមនុស្សនេះ ត្រូវបានយកចិត្តទុកដាក់ និងលើកឡើងដោយសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងអង្គការសិទ្ធិមនុស្សផ្សេងទៀត ហើយការរំលោភបំពានសិទ្ធិមនុស្សនេះ ភាគច្រើនដាក់បន្ទុកទៅលើអាជ្ញាធរ និងក្រុមហ៊ុនវិនិយោគដែលជាអ្នកបានប្រព្រឹត្ត។

ចាប់តាំងពីឆ្នាំ២០០០ មកដល់ឆ្នាំ២០១៣ ពលរដ្ឋជាង ៧សែននាក់ ត្រូវបានគេគណនាថាបានរងផលប៉ះពាល់ពីទំនាស់ដីធ្លីដែលទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច។ [105] ក្នុងទំនាស់ដីធ្លីបែបនេះ ភាគច្រើនប្រជាពលរដ្ឋរងការចាប់ខ្លួន ការចោទប្រកាន់តាមផ្លូវតុលាការ ការគម្រាមកំហែង ការបណ្តេញចេញនាំឲ្យបាត់បង់ដីធ្លីកសិកម្ម និងក្នុងករណីធ្ងន់ធ្ងរមានការប្រើអំពើហិង្សាដោយការបាញ់បោះដោយកាំភ្លើងជាដើមទៀតផង។[106] ជាក់ស្តែង ត្រឹមខែឧសភា ឆ្នាំ២០១១ សហគមន៍ប្រមាណជា ៨១ត្រូវបានបណ្តេញចេញពីលំនៅដ្ឋានរបស់ពួកគេដែលរស់នៅក្នុងទីក្រុងភ្នំពេញ គឺប៉ះផលយ៉ាងតិចណាស់ ៣០,០០៩ម៉ឺនគ្រួសារ។ [107] ភាគច្រើនការបណ្តេញចេញទាំងនេះ ត្រូវបានលើកឡើងថា ធ្វើឡើងដោយមិនបានគោរពតាមវិធានច្បាប់ត្រឹមត្រូវ ដែលត្រូវបានសន្មតថាជាការបណ្តេញចេញដោយខុសច្បាប់ នាំឲ្យប៉ះពាល់ដល់សិទ្ធិលំនៅដ្ឋាន និងសិទ្ធិលើដីធ្លីរបស់ប្រជាពលរដ្ឋ។

[105] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR), *ដីមានជម្លោះ៖ ទិដ្ឋភាពនៃស្ថានភាពដីធ្លី* (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ធ្នូ ២០១៣), ១៩។

[106] សមាគមអាដហុក (ADHOC), *ផ្លូវរបត់?៖ សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា* (ភ្នំពេញ៖ សមាគមអាដហុក, ២៣ កុម្ភៈ ២០១៣), ១៥ដល់១៧។

[107] ដដែល, ២៣។

# ជំពូកទី៣ ដំណោះស្រាយទំនាស់ដីធ្លីនៅអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

ចាប់តាំងពី អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីត្រូវបានបង្កើតមក អាជ្ញាធរជាតិមួយនេះ បានខិតខំប្រឹងប្រែងអនុវត្តការងាររបស់ខ្លួនយ៉ាងសកម្ម ក្នុងការទប់ស្កាត់ និងការដោះស្រាយទំនាស់ដីធ្លី។ ប៉ុន្តែជាលទ្ធផល ភាពជោគជ័យ និងភាពបរាជ័យនៅលាយឡំគ្នា នាំឲ្យបញ្ហានៃទំនាស់ដីធ្លីនៅតែបន្តកើតឡើងឥតឈប់ឈររហូតមកដល់បច្ចុប្បន្ននេះ។ ក្នុងជំពូកទី៣នេះ លើកបង្ហាញអំពីគំរូដំណោះស្រាយសំខាន់ៗដែលអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី [108] ធ្លាប់បានអនុវត្តនាពេលកន្លងមក (៣.១) បន្ទាប់មកធ្វើការវិភាគលើមូលដ្ឋាននៃដំណោះស្រាយរួម ដោយផ្អែកទៅលើបទពិសោធន៍នៃដំណោះស្រាយកន្លងមកនៅខាងលើ (៣.២)។

## ៣.១. ដំណោះស្រាយដែលធ្លាប់អនុវត្តកន្លងមក

ដំណោះស្រាយសំខាន់ៗនាពេលកន្លងមកដែលអាជ្ញាធរជាតិធ្លាប់អនុវត្តមានច្រើន ដែលក្នុងនោះអាចឲ្យធ្វើការបែងចែកជាពីរប្រភេទ គឺដំណោះស្រាយតាមរយៈការដោះស្រាយពាក្យបណ្តឹងដោយផ្អែកទៅលើគោលការណ៍ច្បាប់ដែលមានជាធរមាន (៣.១.១) និងដំណោះស្រាយតាមរយៈការចុះអប់រំ និងផ្សព្វផ្សាយដែលជាវិធានការទប់សង្កាត់ និងបង្ការកុំឲ្យកើតមានទំនាស់ (៣.១.២)។

### ៣.១.១. ដំណោះស្រាយតាមរយៈការដោះស្រាយបណ្តឹង

ដំណោះស្រាយតាមរយៈការដោះស្រាយពាក្យបណ្តឹង គឺជាការដោះស្រាយដោយប្រើប្រាស់គោលការណ៍ច្បាប់ជាធរមានមកធ្វើជាមូលដ្ឋានក្នុងការដោះស្រាយវិវាទ។[109] រាល់ពាក្យបណ្តឹងទាំងអស់ដែលប្តឹងមកអាជ្ញាធរជាតិ ត្រូវដាក់នៅនាយកដ្ឋានទទួលពាក្យបណ្តឹង និងដោះស្រាយទំនាស់ដីធ្លី ដើម្បីធ្វើការចុះលេខពាក្យបណ្តឹងចេញចូលតាមខេត្ត-ក្រុង និងរៀបចំឯកសារសំណុំរឿង។[110] ក្រោយពីទទួលបានពាក្យបណ្តឹង នាយកដ្ឋានទទួល និងដោះស្រាយបណ្តឹងត្រួតពិនិត្យមើលពាក្យបណ្តឹង ហើយអាចកោះអញ្ជើញដើមបណ្តឹង ឬ ចុងចម្លើយពាក់ព័ន្ធឲ្យមកបំពេញឯកសារបន្ថែម ប្រសិនបើយល់ថាឯកសារមិនគ្រប់គ្រាន់ និងធ្វើកំណត់ហេតុសួរយកចម្លើយជាបឋម។ ដើម្បីធានាដល់ការ

[108] ពីពេលនេះតទៅ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី នឹងហៅកាត់ត្រឹមតែ "អាជ្ញាធរជាតិ"។

[109] សុន្ទរកថាឯកឧត្តម ប៊ិន ឈិន ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០០៩ និងទិសដៅបន្តការងារឆ្នាំ២០១០ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី (ថ្ងៃទី ២៧ មករា ២០១០)។

[110] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, លេខ៦៥ អនក្រ.បក, ១៩ កក្កដា ២០០៦, មាត្រា១២ ចំណុច១។

ដោះស្រាយទំនាស់ដីធ្លីឲ្យមានប្រសិទ្ធភាពនិងសុក្រឹតភាព នាយកដ្ឋានទទួល និងដោះស្រាយបណ្តឹងត្រូវប្រមូលនិន្នន័យ និងឯកសារបន្ថែមដែលទាក់ទងនឹងភាគីជំម្លោះ។ ម្យ៉ាងវិញទៀត នាយកដ្ឋានទទួលពាក្យ និងដោះស្រាយបណ្តឹង ធ្វើកំណត់ហេតុដោយសង្ខេបខ្លឹមសារបណ្តឹង លើកអង្គហេតុ និងអង្គច្បាប់ពាក់ព័ន្ធ ហើយផ្តល់យោបល់ជាបឋមជូនអាជ្ញាធរជាតិដើម្បីពិនិត្យ និងសម្រេច។[111] ក្រោយពីពិនិត្យរួចហើយ អាជ្ញាធរជាតិនឹងសម្រេចសេចក្តីថាតើភាគីណាជាអ្នកមានសិទ្ធិលើដីធ្លី។ ប្រសិនបើសេចក្តីសម្រេចនេះមានសុពលភាពអាចអនុវត្តបាន អាជ្ញារធរជាតិត្រូវផ្ញើរសេចក្តីសម្រេចនេះទៅមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ដើម្បីចាត់ចែងធ្វើការចុះបញ្ជីក្បាលដីតាមនីតិវិធី។[112] គួរបញ្ជាក់ដែរថា "រាល់ការសម្រេចរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីគឺ មិននិយាយថាជាការសម្រេចចុងក្រោយ បិទផ្លូវតវ៉ាឡើយ។"[113] មានន័យថា ភាគីដែលមិនសុខចិត្តទៅនឹងសេចក្តីសម្រេចរបស់អាជ្ញាធរជាតិ មានសិទ្ធិពេញទីក្នុងការដាក់ពាក្យបណ្តឹងទៅកាន់តុលាការ។ ប៉ុន្តែត្រង់ចំណុចនេះ មានបញ្ហាទាក់ទងនឹងរយៈពេលការចូលជាធរមាននៃសេចក្តីសម្រេច ទាំងព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី សុទ្ធតែមិនមានកំណត់ទេ។ ចំពោះបញ្ហានេះអាចនឹងត្រូវបានចោទសួរថា តើការផ្តល់លទ្ធភាពឲ្យទៅភាគីដែលមិនសុខចិត្តចំពោះការសម្រេចរបស់អាជ្ញាធរជាតិក្នុងការប្តឹងទៅតុលាការ អាចប្រព្រឹត្តទៅបានចាប់ពីពេលណាដែរ ឬមួយអាចធ្វើបានគ្រប់ពេលឬយ៉ាងណា? បញ្ហានេះទាមទារឲ្យមានការបកស្រាយ និងការកំណត់មួយឲ្យបានច្បាស់លាស់។

### ៣.១.២. ដំណោះស្រាយតាមរយៈការចុះអប់រំ និងផ្សព្វផ្សាយ

ដំណោះស្រាយតាមរយៈការចុះអប់រំ និងផ្សព្វផ្សាយនេះ ធ្វើឡើងក្នុងគោលបំណងខុសពីដំណោះស្រាយតាមរយៈការដោះស្រាយបណ្តឹង។ ដោយហេតុថា ដំណោះស្រាយតាមរយៈការដោះស្រាយបណ្តឹង គឺជាយន្តការដោះស្រាយទំនាស់ ដែលទំនាស់នោះបានកើតឡើងមកហើយ។ ចំណែកឯ ដំណោះស្រាយតាមរយៈការចុះអប់រំ និងផ្សព្វផ្សាយនេះ គឺជាយន្តការទប់ស្កាត់ និងបង្ការ

[111] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, លេខ៦៥ អនក្រ.បក, ១៤ កក្កដា ២០០៦, មាត្រា១២ ចំណុច៨។

[112] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, លេខ៦៥ អនក្រ.បក, ១៤ កក្កដា ២០០៦, មាត្រា១២ ចំណុច៩។

[113] អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, *របាយការណ៍ និងសកម្មភាពការងារឆ្នាំ២០០៩* (ភ្នំពេញ៖ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី នាយកដ្ឋានទប់ស្កាត់ បង្ការ និងអប់រំ, ឧសភា ២០១០), ១៥។

ទំនាស់ដីធ្លី។ ដំណោះស្រាយតាមរយៈការចុះអប់រំ និងផ្សព្វផ្សាយមនៅអាជ្ញាធរជាតិមានដូចជា ការរៀបចំកិច្ចប្រជុំ សិក្ខាសាលា ការផលិតឯកសារអប់រំ ល្ខោនវីដេអូ និងការចុះអប់រំប្រជាពលរដ្ឋ ឲ្យបានយល់ដឹងអំពីបញ្ហា និងផលវិបាកដែលកើតឡើងពីទំនាស់ដីធ្លីជាដើម។ កន្លងមកអាជ្ញាធរជាតិ បានចុះរៀបចំ និងបើកវគ្គអប់រំ ផ្សព្វផ្សាយ ទប់ស្កាត់ និងបង្ការបញ្ហាទំនាស់ដីធ្លីនៅរាជធានី ខេត្តទាំង២៤។ ក្នុងវគ្គអប់រំ ផ្សព្វផ្សាយ ទប់ស្កាត់ និងបង្ការបញ្ហាទំនាស់ដីធ្លីនេះ បានផ្តល់ឱកាសដល់មន្ត្រីក្នុង វគ្គអប់រំបានចូលរួមលើកឡើងជាសំណួរសួរ ពាក់ព័ន្ធនឹងទំនាស់ដីធ្លី។ ម្យ៉ាងវិញទៀត ស្ថិតក្នុងគោលដៅ ទប់ស្កាត់ទំនាស់ដីធ្លីដដែលនេះ អាជ្ញាធរជាតិបានរៀបចំចងក្រងឯកសារពីរប្រភេទ។ ប្រភេទទី១គឺ កម្រងសំណួរ-ចម្លើយពាក់ព័ន្ធនឹងអាជ្ញាធរជាតិ និងគណៈកម្មការសុរិយោដី និងប្រភេទទី២គឺ ស្វែងយល់ អំពីទោសប្បញ្ញត្តិ ស្តីពីបទល្មើសពាក់ព័ន្ធនឹងច្បាប់ភូមិបាល ច្បាប់ព្រៃឈើ ច្បាប់ស្តីពីជលផល និង ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ សរុបចំនួន ៨៧.៧៤៨ក្បាល ជូនទៅអភិបាលរាជធានី/ខេត្ត ក្រុង ស្រុក/ខណ្ឌ ឃុំ/សង្កាត់ និងប៉ុស្តិ៍រដ្ឋបាល។ [114]

## ៣.២. ការវិភាគលើមូលដ្ឋាននៃដំណោះស្រាយរួម

នៅក្នុងចំណុចនេះ នឹងធ្វើការវិភាគជារួមដោយឈរលើដំណោះស្រាយតាមរយៈការដោះ ស្រាយបណ្តឹង និងដំណោះស្រាយតាមរយៈការចុះអប់រំផ្សព្វផ្សាយដែលធ្លាប់មានកន្លងមក ដើម្បី ស្វែងរកមូលដ្ឋានគ្រឹះសមស្របសម្រាប់ជាប្រទីប ឆ្ពោះទៅរកការសន្និដ្ឋានអំពីដំណោះស្រាយមួយ ដែលមានប្រសិទ្ធភាព។

### ៣.២.១. ប្រសិទ្ធភាពនៃដំណោះស្រាយ

ប្រសិទ្ធភាពនៃដំណោះស្រាយនេះ លើកឡើងអំពីប្រសិទ្ធភាពនៃដំណោះស្រាយទាំងពីរ ដែលអាជ្ញាធរជាតិបានធ្វើ និងអនុវត្តកន្លងមក។

ដំណោះស្រាយតាមរយៈការដោះស្រាយបណ្តឹងដែលផ្អែកលើគោលការណ៍ច្បាប់ សំដៅដល់ ការរួមចំណែកកាត់បន្ថយទំនាស់ដីធ្លី ឲ្យមកត្រឹមនៅកម្រិតអប្បបរមា ធានាបានយុត្តិធម៌ជូនភាគីទំនាស់ ហើយនិងរួមចំណែក ថែរក្សាស្ថេរភាពនយោបាយ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។[115] ឆ្លើយតបទៅ នឹងការពោលនៅខាងលើ អាចមានសំណួរចោទសួរថា តើការដោះស្រាយទំនាស់ដីធ្លីនៅអាជ្ញាធរជាតិ

[114] ប៊ិន ឈិន, *របាយការណ៍ និងសកម្មភាពការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីឆ្នាំ២០០៩*, លេខ០៣/១០ របក/អជដ (ភ្នំពេញ៖ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, ១៧ កុម្ភៈ ២០១០) ៣។

[115] អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, *របាយការណ៍ និងសកម្មភាពការងារឆ្នាំ២០០៩* (ភ្នំពេញ៖ អគ្គលេខាធិការដ្ឋាន នៃ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី នាយកដ្ឋានទប់ស្កាត់ បង្ការ និងអប់រំ, ឧសភា ២០១០), ២។

មានប្រសិទ្ធិកម្រិតណាដែរ? មុននឹងឈានទៅដល់ចម្លើយនៃសំណួរនេះ គួរស្វែងយល់អំពីចំនួនពាក្យបណ្តឹងដែលបានប្តឹង ចំនួនពាក្យបណ្តឹងដែលបានដោះស្រាយចប់សព្វគ្រប់ និងពាក្យបណ្តឹងដែលពុំទាន់ទទួលបានការដោះស្រាយជាមុនសិន។ គិតចាប់ពីថ្ងៃបង្កើតអាជ្ញាធរជាតិមកទល់ពេលនេះ អាជ្ញាធរជាតិមានអាយុកាលជាង ៨ឆ្នាំហើយ។ ពាក្យបណ្តឹងដែលអាជ្ញាធរជាតិបានទទួលចន្លោះពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១០(ឆ្នាំ២០០៦ មាន៥៦១ករណី ឆ្នាំ២០០៧ មាន២៥៣ករណី ឆ្នាំ២០០៨ មាន២៤៤ករណី) មានចំនួនសរុបទាំង ១,៤២១ករណី។[116] ក្នុងនោះឆ្នាំ២០០៩ ទាំងបណ្តឹងទទួលបានពីប្រជាពលរដ្ឋផ្ទាល់ ទាំងបណ្តឹងទទួលបានពីស្ថាប័ននានាសរុបមាន ២១៣ករណី។ បណ្តឹងដោះស្រាយរួចមានចំនួន ១០២ករណី កំពុងដោះស្រាយមានចំនួន ១២៩ករណី ហើយបណ្តឹងដែលមិនស្ថិតនៅក្នុងសមត្ថកិច្ចអាជ្ញាធរជាតិមានចំនួន ១០៨ករណីដែលត្រូវបង្វែរចេញទៅវិញ។[117] ចំណែកក្នុងឆ្នាំ២០១០ បណ្តឹងសរុបមានចំនួន ១៥០ករណី ក្នុងនោះដោះស្រាយរួចមានចំនួន ៥៥ករណី កំពុងដោះស្រាយ ១៥៣ករណី ហើយ៧១ករណីត្រូវបានបង្វែរ។[118] មើលលើចំនួនពាក្យបណ្តឹង ចាប់ពី២០០៦មកត្រឹម២០១០ឃើញថា ចំនួនការដាក់បណ្តឹងមានការថយចុះរៀងរាល់ឆ្នាំ ម្យ៉ាងវិញទៀតបណ្តឹងដែលបានដោះស្រាយរួចក៏មានច្រើនគួរកត់សម្គាល់ផងដែរ។ ដូច្នេះ ដំណោះស្រាយតាមរយៈការដោះស្រាយទំនាស់ដីធ្លីនៅអាជ្ញាធរជាតិ អាចនិយាយបានថាមានប្រសិទ្ធភាព។ ប៉ុន្តែ ការសន្និដ្ឋានបែបនេះមិនមែនមានន័យថាត្រឹមត្រូវទាំងស្រុងនោះទេ ជួនកាលការថយចុះនៃការដាក់ពាក្យបណ្តឹងអាចបណ្តាលមកពីសំណុំរឿងនៅគណៈកម្មការសុរិយោដីមានការកកស្ទះក៏ថាបាន។ មួយវិញទៀត ទោះបីជាបណ្តឹងដែលបានដោះស្រាយមានចំនួនកើនឡើងក៏ដោយ ក៏មិនប្រាកដថាភាគីដែលចាញ់ក្តីមិនបណ្តឹងបន្តទៅតុលាកាឯណា? ជាងនេះទៅទៀត ទាក់ទងនឹងសេចក្តីសម្រេចនៃការដោះស្រាយទំនាស់នេះ អ្នកដាក់ពាក្យបណ្តឹងមួយចំនួនបានលើកឡើងថា "សេចក្តីសម្រេចតែងតែមានពាក់ព័ន្ធនឹងការជ្រៀតជ្រែកផ្នែកនយោបាយ។"[119] តាមរយៈនេះ ប្រសិទ្ធភាពនៃដំណោះស្រាយតាមរយៈការដោះស្រាយបណ្តឹងនៅមានកម្រិតទាប មិនទាន់ឆ្លើយតបនឹងស្ថានភាពទំនាស់ដីធ្លីនាពេលបច្ចុប្បន្នទេ។

---

[116] ហាប់ ផល្វី, កំណត់ត្រាព័ត៌មានថ្មីៗទាក់ទងនឹងដីធ្លី (ភ្នំពេញ៖ ៤ កុម្ភៈ ២០១៤)។

[117] ប៊ិន ឈិន, *របាយការណ៍ និងសកម្មភាពការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីឆ្នាំ២០០៩*, លេខ០៣/១០ របក/អជដ (ភ្នំពេញ៖ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, ១៧ កុម្ភៈ ២០១០), ៤។

[118] ប៊ិន ឈិន, *របាយការណ៍ និងសកម្មភាពការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីឆ្នាំ២០១០*, ០០៣/១១របក/អជដ (ភ្នំពេញ៖ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, ២៥ កុម្ភៈ ២០១១), ២៩។

[119] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR), *ដីមានជម្លោះ ទិដ្ឋភាពនៃស្ថានភាពដីធ្លី* (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ធ្នូ ២០១៣), ៤០។

ចំណែកដំណោះស្រាយតាមរយៈការចុះអប់រំ និងផ្សព្វផ្សាយវិញ គឺជាយន្តការដែលមាននិន្នាការទប់ស្កាត់ បង្ការ និងកាត់បន្ថយទំនាស់។ វិធីសាស្រ្ត និងមធ្យោបាយរបស់ដំណោះស្រាយនេះរួមមានការចុះអប់រំប្រជាពលរដ្ឋឲ្យយល់ដឹងពីផលវិបាកនៃទំនាស់ដីធ្លី និងការបោះពុម្ពផ្សាយនូវកម្រងសំណួរ-ចម្លើយ រួមទាំងទោសប្បញ្ញត្តិពាក់ព័ន្ធបទល្មើសរំលោភយកដីរដ្ឋជាដើម។ ដំណោះស្រាយតាមរយៈការអប់រំ និងការផ្សព្វផ្សាយដោយប្រើវិធីសាស្រ្តខាងលើនេះ ពិតជាបានចូលរួមកាត់បន្ថយនូវទំនាស់ដីធ្លី។ ប៉ុន្តែប្រសិទ្ធភាពនៃការទប់ស្កាត់ និងបង្ការទំនាស់ដោយវិធីសាស្រ្តខាងលើនេះពុំទាន់ឆ្លើយតបទៅនឹងស្ថានភាពទំនាស់ដីធ្លីជាក់ស្តែងនៅឡើងទេ ហើយជម្លោះដីធ្លីនៅតែមិនមានការថយចុះ តែបែរជានៅតែបន្តកើនឡើងឥតឈប់ឈរទៅវិញ។ ជាក់ស្តែង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាបានរកឃើញថា ជម្លោះដីធ្លីនៅតែបន្តកើនឡើង ហើយជម្លោះដែលនៅមិនទាន់ដោះស្រាយនៅតែបន្តកើនឡើងផងដែរ។

> រវាងឆ្នាំ២០០៧ និងឆ្នាំ២០១១ មានត្រឹមតែ ៣១%នៃជម្លោះដីធ្លីសរុបដែលបានឆ្លងកាត់ដំណើរការដោះស្រាយជម្លោះ ខណៈពេលដែលមាន ៥៧%ទៀតមិនដែលត្រូវបានឆ្លងកាត់ដំណើរការដោះស្រាយជាផ្លូវការណាមួយនោះទេ ថ្វីបើអ្នកដាក់ពាក្យប្តឹងបានលើកបញ្ហានេះទៅកាន់អាជ្ញាធរ ឬតុលាការក៏ដោយ។ បន្ថែមពីលើនោះ ក្នុងចំណោមករណីចំនួន ៨៧ ដែលមានជម្លោះ ដែលបានចូលមកក្នុងដំណើរការដោះស្រាយជម្លោះ មានត្រឹមតែ ៤៦% ប៉ុណ្ណោះដែលត្រូវបានចងក្រងជាឯកសារថាត្រូវបានដោះស្រាយបានយ៉ាងពេញលេញ...។[120]

សរុបសេចក្តីមក ដំណោះស្រាយតាមរយៈការដោះស្រាយបណ្តឹង និងដំណោះស្រាយតាមរយៈការចុះអប់រំ និងផ្សព្វផ្សាយ គឺជាផ្នែកមួយដ៏សំខាន់។ ដោយហេតុថា ដំណោះស្រាយតាមរយៈការដោះស្រាយបណ្តឹង ជាយន្តការដោះស្រាយទំនាស់ដែលបានកើតឡើងមកហើយ ដែលធ្វើយ៉ាងណាឲ្យទំនាស់ដីធ្លីនោះ អាចមានច្រកចេញ ឬដំណោះស្រាយខ្លះៗជាជាងទុកឲ្យទំនាស់វិវត្តខ្លួនក្លាយទៅជាវិបត្តកាន់តែធ្ងន់ធ្ងរខ្លាំងជាងនេះ។ ដំណោះស្រាយបណ្តឹងនេះ មិនអាចធានាដល់និរន្តភាពក្នុងការលុបបំបាត់ទំនាស់ដីធ្លីបានទេ ព្រោះថាការដោះស្រាយបណ្តឹង ជាយន្តការដោះស្រាយវិវាទ មិនមែនជាយន្តការទប់ស្កាត់ទំនាស់ទេ។ ចំពោះដំណោះស្រាយតាមរយៈការចុះអប់រំ និងផ្សព្វផ្សាយវិញ មាននិន្នាការទប់ស្កាត់ និងបង្ការទំនាស់ធ្វើយ៉ាងណាឲ្យទំនាស់ដីធ្លីស្ថិតក្នុងកម្រិតអប្បបរមា។

[120] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR), ដីមានជម្លោះ ទិដ្ឋភាពនៃស្ថានភាពដីធ្លី (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ធ្នូ ២០១៣), ៤០និង៤១។

តែទោះជាយ៉ាងណា ដំណោះស្រាយនេះ នៅតែពុំទាន់ឆ្លើយតបនឹងស្ថានភាពជាក់ស្តែងនៃទំនាស់ដីធ្លីនៅឡើង។

ដូចនេះ ដើម្បីទប់ស្កាត់ បង្ការ និងអាចឈានដល់ការលុបបំបាត់បានទាំងស្រុងនូវទំនាស់ដីធ្លី អាជ្ញាធរជាតិគួរតែរិះគិតពិចារណា ស្រាវជ្រាវឲ្យឃើញនូវឬសគល់ចម្បងដែលជាហេតុនាំឲ្យកើតឡើងនូវទំនាស់ដីធ្លី។ បន្ទាប់មក គួរពិចារណា និងចាត់វិធានការណាមួយឲ្យបានសមស្របចំពោះឬសគល់នៃទំនាស់ដោយឈរលើគោលការណ៍ធានានូវនិរន្តភាពលើប្រសិទ្ធភាពដោះស្រាយ។

# សេចក្តីសន្និដ្ឋាន

ភាពបរាជ័យនៃការចុះបញ្ជីដីធ្លីនៅកម្ពុជា នាំឲ្យដីធ្លីនៅកម្ពុជាមិនទាន់មានព្រំប្រទល់ច្បាស់លាស់ ដែលជាហេតុនាំឲ្យមានការបែងចែករវាងដីរដ្ឋ និងដីឯកជនរបស់រដ្ឋមិនអាចធ្វើទៅបាននៅឡើងទេ។ តាមស្ថានភាពនេះ នាំឲ្យកម្ពុជាបច្ចុប្បន្ននេះ មានការកាន់កាប់ដីធ្លីនៅលាយឡំគ្នា ជាពិសេសនោះគឺ បញ្ហាទំនាស់ដីធ្លីគឺជាបញ្ហាដ៏ធ្ងន់ធ្ងរ និងដោះស្រាយមិនចេះចប់មិនចេះហើយ ដែលទាមទារឲ្យមាន ដំណោះស្រាយសមស្របមួយ។

កត្តាសំខាន់ៗដែលនាំឲ្យកើតមានទំនាស់ដីធ្លីរួមមានពីរ គឺទីមួយ កត្តាកើតចេញពីប្រជាពលរដ្ឋ។ កត្តាកើតចេញពីប្រជាពលរដ្ឋនេះ សំដៅទៅលើសកម្មភាពប្រជាពលរដ្ឋដែលបានចូលកាន់កាប់ដីរដ្ឋ និងដីធ្លីឯកជនដោយខុសច្បាប់។ ហើយមូលហេតុដែលធ្វើឲ្យមានការចូលកាន់កាប់ដីរដ្ឋ និងដីធ្លីឯកជនរួមមាន ភាពក្រីក្រ និងមូលហេតុផ្សេងទៀតដូចជាចំណេះដឹងជាដើម។ និងទីពីរ កត្តាដែលកើតចេញពីអាជ្ញាធរ។ កត្តាកើតចេញពីអាជ្ញាធរនេះរួមមាន ភាពធ្វេសប្រហែសក្នុងការគ្រប់គ្រងដីធ្លី ការគ្រប់គ្រងដីធ្លីគ្មានប្រសិទ្ធភាព។ ពិសេសជាងនេះទៀតនោះគឺ ការផ្តល់សម្បទានដីសេដ្ឋកិច្ចត្រូវបានធ្វើឡើងដោយមិនបានអនុវត្តតាមគោលការណ៍ច្បាប់ឲ្យបានពេញលេញ។ ពិសេសនោះ ការផ្តល់សម្បទានដីសេដ្ឋកិច្ច ធ្វើដោយមិនបានពិគ្រោះយោបល់ និងវាយតម្លៃអំពីផលប៉ះពាល់ទុកជាមុនទេ។

ដីធ្លីដែលជាកម្មវត្ថុនៃទំនាស់ មានលក្ខណៈពិសេសប្លែកពីគ្នា តែទោះជាយ៉ាងណា ដីដែលជាកម្មវត្ថុនៃទំនាស់អាចកំណត់បានថា ជាដីធ្លីទាំងឡាយណាដែលពុំទាន់ចុះបញ្ជី ទាំងកម្មវិធីចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ។ លើសពីនេះទៅទៀត ដីធ្លីដែលពុំទាន់ចុះបញ្ជីទាំងអស់នេះ គឺជាដីធ្លីមានការជាប់ទាក់ទងនឹងដីធ្លីដែលអាជ្ញាធរបានសម្រេចផ្តល់ជាដីសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុនវិនិយោគ។ តាមរយៈការកើតឡើងនូវទំនាស់ដីធ្លីនេះវាបានផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងចំពោះប្រជាពលរដ្ឋដែលកំពុងកាន់កាប់ដីធ្លី និងសង្គមជាតិទាំងមូល។ ផលប៉ះពាល់ចំពោះប្រជាពលរដ្ឋរួមមាន ការបាត់បង់ដីធ្លីកំពុងកាន់កាប់ ទាំងដីលំនៅដ្ឋាន និងដីកសិកម្ម ដោយសារការបណ្តេញចេញ។ ផលប៉ះពាល់ចំពោះសង្គមជាតិវិញរួមមាន រាំងស្ទះដល់ការអភិវឌ្ឍសង្គម និងការរំលោភសិទ្ធិមនុស្ស។ ផលប៉ះពាល់ដល់សង្គមមានដូចជា សង្គមជួបនឹងវិបត្តដីធ្លីនាំឲ្យកើតមានការតវ៉ាទាមទារដីធ្លីគ្រប់ទីកន្លែង។ ចំពោះផលប៉ះលើសិទ្ធិមនុស្សវិញ ជាទូទៅត្រូវបានលើកឡើងថា មានការរំលោភសិទ្ធិមនុស្សដោយសារការបណ្តេញចេញដោយបង្ខំ ការប្រើហិង្សា ការបាញ់បោះដោយប្រើប្រាស់កាំភ្លើង និងការប្រើកម្លាំងបង្ក្រាបផ្សេងទៀតនៅពេលមានការតវ៉ាទាមទារដីធ្លីកើតឡើងម្តងៗ។

ឆ្លើយតបនឹងបញ្ហាទំនាស់ដីធ្លីដែលចេះតែកើនឡើងជារៀងរាល់ថ្ងៃនេះ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីត្រូវបានបង្កើតឡើងដែលបានភារកិច្ចចម្បងៗដូចជា ទទួលពាក្យបណ្ដឹងដែលហួសពីសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ និងទទួលពាក្យបណ្ដឹងពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធទំនាស់ដីធ្លី ទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លីតាមរយៈការអប់រំ ផ្សព្វផ្សាយឲ្យសាធារណៈជនយល់ដឹងអំពីផលវិបាកបណ្ដាលមកពីទំនាស់ដីធ្លី និងមានវិធានការដាក់វិន័យចំពោះជនល្មើស ដែលបានរំលោភបំពានលើដីធ្លីដោយខុសច្បាប់ជាដើម។ ចំពោះដំណោះស្រាយក្នុងការដោះស្រាយទំនាស់ដីធ្លី អាជ្ញាធរជាតិមានយន្តការពីរ ទីមួយយន្តការដោះស្រាយបណ្ដឹង និងទីពីរ យន្តការទប់ស្កាត់ និងបង្ការទំនាស់តាមរយៈការចុះអប់រំផ្សព្វផ្សាយ។ តាមការវាយតម្លៃក្នុងការស្រាវជ្រាវនេះបង្ហាញថា ដំណោះស្រាយទាំងពីរខាងលើដែលអាជ្ញាធរជាតិបាននិងកំពុងអនុវត្ត មិនសូវទទួលបានប្រសិទ្ធភាពប៉ុន្មានទេ។ ពីព្រោះថា យន្តការដោះស្រាយទំនាស់មិនមែនជាយន្តការទប់ស្កាត់ និងបង្ការទំនាស់ទេ ទោះបីជាខិតខំប្រឹងប្រែងដោះស្រាយទំនាស់ដីធ្លីយ៉ាងណា ទំនាស់ដីធ្លីនៅតែមិនអាចលុបបំបាត់បានដដែល។ ចំណែក យន្តការទប់ស្កាត់ និងបង្ការតាមរយៈការចុះអប់រំ និងផ្សព្វផ្សាយវិញ មានប្រសិទ្ធភាពតិចតួចស្ដួចស្ដើងនៅឡើយ។ ហេតុដូចនេះ ទើបទំនាស់ដីធ្លីនៅតែបន្តកើនឡើងដដែល។

តាមរយៈការស្វែងយល់លើដំណោះស្រាយកន្លងមក អាជ្ញាធរជាតិគួរតែធ្វើការសិក្សាស្រាវជ្រាវឲ្យបានលម្អិត និងស៊ីជម្រៅបំផុតធ្វើយ៉ាងរកឲ្យឃើញនូវប្រភព ឬសគល់នៃទំនាស់ បន្ទាប់ពីរកឃើញប្រភព ឬសគល់នៃទំនាស់ហើយ ត្រូវពិចារណារកដំណោះស្រាយណាមួយសមស្របបំផុតដើម្បីធានាដល់និរន្តភាពលើប្រសិទ្ធភាពដោះស្រាយទំនាស់។

# អនុសាសន៍

តាមរយៈការស្វែងយល់ និងបទពិសោធន៍ក្នុងការស្រាវជ្រាវខាងលើ អាចទទួលបាន អនុសាសន៍សំខាន់ៗសម្រាប់ជាប្រយោជន៍ដល់ការផ្តល់ដំណោះស្រាយសមស្របដូចខាងក្រោម។

ជាដំបូង អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធនឹងការចុះកិច្ចសន្យាផ្តល់សម្បទានដីសេដ្ឋកិច្ចទាំងអស់គួរតែបញ្ឈប់នូវការផ្តល់សម្បទានដីសេដ្ឋកិច្ចទាំងឡាយណា ដែលធ្វើឡើយតាមសំណើរមិនមានការអំពាវនាវ ដោយមិនបានសិក្សាស្រាវជ្រាវឲ្យបានលំអិតទាក់ទងនឹងផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមកិច្ច។ ដើម្បីជៀសវាងការផ្តល់សម្បទានដីសេដ្ឋកិច្ចតាមសំណើរមិនបានអំពាវនាវអាជ្ញាធរមានសមត្ថកិច្ចទាំងអស់ ត្រូវងាកទៅរកការផ្តល់សម្បទានដីសេដ្ឋកិច្ចតាមសំណើរមានការអំពាវនាវ ដោយខិតខំបំពេញការងាររបស់ខ្លួនឲ្យបានល្អ និងធ្វើយ៉ាងណារៀបចំឯកសារក្នុងការរៀបចំដីធ្លីទុកជាមុន មុននឹងចុះកិច្ចសន្យាផ្តល់ដីសម្បទានសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុន។ ការធ្វើបែបនេះអាចកាត់បន្ថយផលប៉ះពាល់ចំពោះបរិស្ថាន និងសង្គមកិច្ច ជាពិសេសអាចជៀសផុតពីការកើតឡើងនូវទំនាស់ដីធ្លី។

បន្ទាប់មកគឺ ផ្តល់ដំណោះស្រាយណាមួយដែលមានលក្ខណៈសមស្របសាកសមល្មមអាចទទួលយកបានទោះបីជាកើតមានទំនាស់ដីធ្លីនៅលើដីសម្បទានសេដ្ឋកិច្ចក៏ដោយ។ យន្តការនៃដំណោះស្រាយបែបនេះ អាចបញ្ចៀសនូវការរំលោភលើសិទ្ធិលំនៅដ្ឋាន ដែលអង្គការសង្គមស៊ីវិលតែងតែលើកយកមកពិភាក្សា។ លើសពីនេះទៀត អាចបញ្ចៀស និងរារាំងកុំឲ្យកើតមានវិបត្តិសង្គមតាមរយៈប្រជាពលរដ្ឋគ្មានដីធ្លីសម្រាប់ស្នាក់នៅ និងដីសម្រាប់ដាំដុះ។

ជាចុងក្រោយគឺ ការព្យាយាមទប់ស្កាត់ បង្ការការពារធ្វើយ៉ាងណាឲ្យទំនាស់ដីធ្លីស្ថិតក្នុងកម្រិតអប្បបរមា ហើយនឹងឈានដល់ការលុបបំបាត់ចោលទាំងស្រុងនូវទំនាស់ដីធ្លីនៅកម្ពុជា។ ដំណោះស្រាយដែលមានភាពរឹងមាំ និងមាននិរន្តភាពជាងគេនោះគឺ ការជំរុញឲ្យមានការចុះបញ្ជីលើកដំបូងឲ្យបានជោគជ័យ និងឆាប់រហ័សតាមអ្វីដែលអាចធ្វើបាន។ ដើម្បីឲ្យការងារនេះទទួលបានជោគជ័យ រាជរដ្ឋាភិបាលតាមរយៈក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវខិតខំអនុវត្តការងារ និងពង្រឹងសមត្ថភាពការងាររបស់ខ្លួនឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។ ស្ថិតក្នុងក្របខ័ណ្ឌនេះ អាជ្ញារធរជាតិដោះស្រាយទំនាស់ដីធ្លីនៅតែអាចបន្តអនុវត្តការងារដោះស្រាយបណ្តឹងបានដដែល។

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។

រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា, ៣០ មេសា ១៩៨៩។

រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, លេខ០១ ក្រ, ២៧ មិថុនា ១៩៨១។

ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១។

ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២។

ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, នស/រកត/០២០៦/០៩៧, ២៦ កុម្ភៈ ២០០៦។

អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, លេខ៦៥អនក្រ.បក, ១៤ កក្កដា ២០០៦។

អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច, លេខ១៤៦អនក្រ/បក, ២៧ ធ្នូ ២០០៥។

អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨អនក្រ/បក, ០៧ តុលា ២០០៥។

អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី, លេខ៤៧អនក្រ/បក, ៣១ ឧសភា ២០០២។

អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ១១អនក្រ/បក, ២២ មីនា ២០០០។

អនុក្រឹត្យស្តីពីការប្រកាសទ្រព្យសម្បត្តិរដ្ឋ, លេខ៥៣អនក្រ/បក, ២៧ មិថុនា ១៩៩៥។

អនុក្រឹត្យស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា, លេខ២៥អនក្រ ២២ មេសា ១៩៨៩។

អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រើប្រាស់ដីកសិកម្ម, លេខ០៦ អនក្រ, ០៦ ឧសភា ១៩៨៥។

សារាចរស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់, លេខ០២សរ, ២៦ កុម្ភៈ ២០០៧។

សារាចរស្តីពីកម្មសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋបច្ចុប្បន្ន និងកម្មសិទ្ធិសាធារណៈ, លេខ០១សរ, ០៣ កក្កដា ១៩៩៣។

សារាចរណែនាំស្តីពីវិធានការចំពោះសកម្មភាពរំលោភយកដីសាធារណៈ, លេខ០៣សរណន, ១៤ ធ្នូ ១៩៩២។

សារាចរស្តីពីការផ្តល់កម្មសិទ្ធិ និងលក់ផ្ទះសំបែងជូនប្រជាពលរដ្ឋក្នុងរដ្ឋធានីភ្នំពេញ, លេខ០២ សរ, ០៧ កុម្ភៈ ១៩៩១។

សេចក្តីណែនាំស្តីពីវិធានការទប់ស្កាត់ការកាប់រានដីព្រៃឈើ និងការចេញលិខិតបញ្ជាក់ការទិញលក់ដីក្នុងតំបន់ការពារធម្មជាតិ, លេខ០០១សណន, ០៩ មករា ២០០៧។
សេចក្តីណែនាំអនុវត្តបទបញ្ជាស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ, លេខ៦២៣ដនស/សជ, ១៦ មិថុនា ២០០៤។
សេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ០៣ មិថុនា ១៩៨៩។
សេចក្តីប្រកាសស្តីពីវិធានការលុបបំបាត់ភាពអានាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់ដីធ្លី, លេខ០៦ប្រក, ២៧ កញ្ញា ១៩៩៩។
សេចក្តីប្រកាសស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអានាធិបតេយ្យក្នុងវិស័យព្រៃឈើ, លេខ០១ប្រក, ២៥ មករា ១៩៩៩។
សេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, មេសា ១៩៨៩។
បទបញ្ជាស្តីពីការទប់ស្កាត់ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកមកធ្វើជាកម្មសិទ្ធិ, លេខ០១បប, ១០ ឧសភា ២០០៦។
បទបញ្ជាស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ, លេខ០១បប, ០៩ មិថុនា ២០០៤។
សេចក្តីជូនដំណឹងស្តីពីការផ្អាកជាបណ្តោះអាសន្ននូវការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលើដីព្រៃឈើគ្រប់ប្រភេទ, លេខ០៩សជណ/សជ, ០៤ កក្កដា ២០០៦។
លិខិតរបស់សម្តេចនាយករដ្ឋមន្ត្រីទី១ផ្ញើជូនសម្តេចនាយករដ្ឋមន្ត្រីទី២ស្នើឲ្យការសុំកាន់កាប់ដីធ្លីឆ្លងកាត់ទីស្តីការគណៈរដ្ឋមន្ត្រី, លេខ៩១៨ខុទ្ទ/៩៥, ១៦ មិថុនា ១៩៩៥។
លិខិតរបស់គណៈរដ្ឋមន្ត្រីស្តីពីករណីបញ្ហាទំនាស់កម្មសិទ្ធិដីធ្លីរវាងអាជ្ញាធរ និងប្រជារាស្ត្រ, លេខ១០៥២សជណ/សរ, ០៥ កក្កដា ១៩៩៥។
លិខិតរបស់ក្រសួងបរិស្ថានស្តីពីបញ្ហាកម្មសិទ្ធិដីធ្លីក្នុងតំបន់ការពារធម្មជាតិ, លេខ១៧១៩បស្ថ, ១៤ កញ្ញា ១៩៩៥។

## **សៀវភៅ**

ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ. ២០១១. *រដ្ឋធម្មនុញ្ញទាំងឡាយនៃកម្ពុជា*. ភ្នំពេញ៖ ក្រុមប្រឹក្សាធម្មនុញ្ញ។
ពុទ្ធសាសនបណ្ឌិត្យ. ១៩៦៨. *វចនានុក្រមខ្មែរ*. ភ្នំពេញ៖ កម្ពុជា។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR). ២០១៤. *មេរៀនស្តីពី សិទ្ធិដីធ្លីក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១.* ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។

សមាគមអាដហុក (ADHOC). ២០១៣. *ផ្លូវរបត់?៖ សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា.* ភ្នំពេញ៖ សមាគមអាដហុក។

ហាប់ ផល្ធី. ២០១០. *កម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងដីធ្លី.* ភ្នំពេញ។

ឥន សុផល. ២០១៣. *គន្លឹះនៃវិធីសាស្ត្រស្រាវជ្រាវសម្រាប់សរសេរសារណា និងនិក្ខេបបទ.* ភ្នំពេញ។

ឥន្ទ ឱមសាម៉េង, ហ៊ីង គឹមឡេង, ឈុន ពហុ, ទេព សុខ, ស្រី ម៉ាលីន, ស្រ៊ិន ឌីណា និងមៀច សុផារី. ២០១២-២០១៣. *ភូមិវិទ្យាសេដ្ឋកិច្ច និងមនុស្សនៃប្រទេសកម្ពុជា.* ភ្នំពេញ៖ ជោគជ័យ។

East-West Management Institute. ២០០៥. *ច្បាប់ភូមិបាលកម្ពុជា៖ សៀវភៅសិក្សា និងស្រាវជ្រាវ.* ភ្នំពេញ។

## ទិនានុប្បវត្តិ និងអត្ថបទបោះពុម្ពផ្សាយផ្សេងទៀត

Hap, Phalthy. 2011. The Implementation of Cambodia's Laws on Lan Tenure [ការអនុវត្តច្បាប់កម្ពុជាលើការកាន់កាប់ដីធ្លី]. Cambodian Yearbook of Comparative Legal Studies Vol.2: 189-190។

ហ៊ែល ចំរើន. ២០០៥. ទស្សនាទាននៃសិទ្ធិលើកម្មសិទ្ធិដីធ្លីនៅកម្ពុជា. *វិស្សបវត្តិ* ២០០២-២០០៣៖ ២៥-៣៨។

ហ៊ែល ចំរើន. ២០០៨. ពិចារណាមួយលើវិវាទដីធ្លីនៅកម្ពុជា. *វិស្សបវត្តិ* ២០០៧៖ ៤៧-៧១។

## របាយការណ៍

ប៊ិន ឈិន. ២០១១. *របាយការណ៍ ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីឆ្នាំ២០១០*, លេខ០០៣/១១របក/អជដ. ភ្នំពេញ៖ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, ២៥ កុម្ភៈ។

ប៊ិន ឈិន. ២០១០. *របាយការណ៍ និងសកម្មភាពការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីឆ្នាំ២០០៩*, លេខ០៣/១០របក/អជដ. ភ្នំពេញ៖ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, ១៧ កុម្ភៈ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR). ២០១៣. *កម្ពុជា៖ ដីមានជម្លោះ ទិដ្ឋភាពនៃស្ថានភាពដីធ្លី.* ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ធ្នូ។

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី. ២០១០. *របាយការណ៍ និងសកម្មភាពការងារឆ្នាំ២០០៩.* ភ្នំពេញ៖ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី នាយកដ្ឋានទប់ស្កាត់ បង្ការ និងអប់រំ, ឧសភា។

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី. ២០០៨. *របាយការណ៍ស្តីពី លទ្ធផលនៃការអនុវត្តយុទ្ធសាស្រ្ត ចតុកោណរបស់រាជរដ្ឋាភិបាល[សម្រាប់]នីតិកាលទី៣ នៃរដ្ឋសភា ២០០៤-២០០៧ និង ទិសដៅបន្ត ពី២០០៨-២០១៣.* ភ្នំពេញ៖ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី,០៧ មេសា។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR). *២០១៣. របាយការណ៍គោលនយោបាយកំណែទម្រង់ដីធ្លី៖ របបគំហើញពីកិច្ចពិភាក្សាតុមូល និងវេទិកាគោលនយោបាយ.* ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិ មនុស្សកម្ពុជា, ធ្នូ។

លីកាដូ (LICADHO). *ឆ្នាំ២០១៤ នាំមកនូវរលកថ្មីនៃជម្លោះដីធ្លីនៅកម្ពុជា.* ភ្នំពេញ៖ លីកាដូ។

សមាគមអាដហុក (ADHOC). ២០១២. *របាយការណ៍សិទ្ធិដីធ្លី និងលំនៅដ្ឋានឆ្នាំ២០១១.* ភ្នំពេញ៖ មីនា។

## គេហទំព័រ

ឆាយ ថន. ២០១១. *ការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា៖ បច្ចុប្បន្នភាព ឆ្នាំ ២០១០.* ភ្នំពេញ៖ ក្រសួងផែនការ, មីនា, http://www.mop.gov.kh/Home/CMDGs/tabid/156/Default.aspx។

Word Food Programme, “Poverty: Cambodia” [ភាពក្រីក្រ៖ ប្រទេសកម្ពុជា], http://www.foodsecurityatlas.org/khm/country/access/poverty។

ហ៊ុន សែន. ២០១៤.*របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៣ស្តីពីការសម្រេចបានគោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា.* ភ្នំពេញ៖ ក្រសួងផែនការ, ១១ មេសា, http://www.mop.gov.kh/Home/CMDGs/tabid/156/Default.aspx។

Rural Poverty Portal, Rural Poverty in Cambodia [ភាពក្រីក្រនៃជនបទនៅកម្ពុជា], http://www.ruralpovertyportal.org/country/home/tags/cambodia។

ហង្ស សារយុត. "ពលរដ្ឋនៅព្រះវិហារខ្វះដីធ្វើស្រែរដូវវស្សាដោយសារជម្លោះដីជាមួយក្រុមហ៊ុន” . វិទ្យុអាស៊ីសេរី, ផ្សាយថ្ងៃទី១៥ មិថុនា ២០១៥, http://www.rfa.org/khmer/news/land/preah-vihear-06152015050445.html (ចូលទស្សនាថ្ងៃទី១២ កក្កដា ២០១៥)។

ហាប់ ផល្ធី. ២០១៥. *ការដោះស្រាយវិវាទដីធ្លី*. ភ្នំពេញ, https://phalthy.files.wordpress.com/2006/11/w14-land-dispute-resolutions.pdf (ចូលទស្សនានៅថ្ងៃទី ៣ កក្កដា២០១៥ )។

ហាប់ ផល្ធី. ២០១៥. *ការចុះបញ្ជីដីធ្លី*. ភ្នំពេញ, https://phalthy.files.wordpress.com/2006/11/w10-land-registration.pdf (ចូលទស្សនាថ្ងៃទី ១២ កក្កដា ២០១៥)។

ហាប់ ផល្ធី. ២០១៥. *ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ*. ភ្នំពេញ, https://phalthy.files.wordpress.com/2006/11/w11-management-of-state-property.pdf (ចូលទស្សនានៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥)។

## ឯកសារមិនបានបោះពុម្ព និងឯកសារផ្សេងៗទៀត

អ៊ឹម ឈុនលឹម. *បទអន្តរាគមន៍ស្តីពី លទ្ធផលនៃការអនុវត្តកម្មវិធីកំណែទម្រង់ដីធ្លី ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធិភាពសិទ្ធិសីទជាតិរបស់រដ្ឋាភិបាល* (៣០-៣១ ខែឧសភា និង ០១ ខែមិថុនា ឆ្នាំ២០០៨)។

ហាប់ ផល្ធី. ២០១៤. កំណត់ត្រាព័ត៌មានថ្មីៗទាក់ទងនឹងដីធ្លី. ភ្នំពេញ៖ ៤ កុម្ភៈ។